ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ការគ្រប់គ្រងប្រាក់

## (សៀវភៅសិស្ស)



**បំណិនជីវិតសម្រាប់សិស្សមធ្យមសិក្សាបឋមភូមិ**
**គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា**

USAID
ជំនួយពីពលរដ្ឋអាមេរិក

អង្គការអប់រំពិភពលោក
WORLD EDUCATION

ឧបត្ថម្ភដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍអន្តរជាតិ
រៀបចំដោយ អង្គការអប់រំពិភពលោក សហការជាមួយអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា

**គណៈកម្មការអភិវឌ្ឍសៀវភៅ**
**"ការគ្រប់គ្រងប្រាក់"**

**គណៈកម្មការនិពន្ធ និងរៀបរៀង**

១. លោកស្រី អេលិន ជោច (Eileen St. George)

២. លោក ចាន់ ណារិន

៣. លោក សៅ ប៊ុនធឿន

**គណៈកម្មការកែសម្រួល**

១. លោក ឈុំ វណ្ណធន

២. លោកស្រី មុំ មេត

៣. លោក ប៉ុល សុរិទ្ធ

**គណៈកម្មការពិនិត្យ**

១. លោក ព្រំ វិបុល

២. លោក មាស ជុតិមា

៣. លោក ហួត នរៈ

ឧបត្ថម្ភថវិកាដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិចដើម្បីអភិវឌ្ឍអន្តរជាតិ (USAID)

សហការរៀបចំដោយ

អង្គការអប់រំពិភពលោក និង ក្រសួងអប់រំ យុវជន និងកីឡា

# មាតិកា

ទំព័រ


អារម្ភកថា ........................................................................ ០១

មេរៀនទី ១ : តើខ្ញុំប្រើប្រាស់ប្រាក់យ៉ាងដូចម្ដេច?........................................០២

មេរៀនទី ២ : តើខ្ញុំបានប្រាក់មកដោយរបៀបណា?........................................០៧

មេរៀនទី ៣ : គោលបំណង តម្លៃ និងអាទិភាព ...........................................១២

មេរៀនទី ៤ : ទម្លាប់នៃការចំណាយប្រាក់ .................................................១៨

មេរៀនទី ៥ : ការបង្កើតសៀវភៅកត់ត្រាការចំណាយប្រចាំថ្ងៃ ...........................២០

មេរៀនទី ៦ : ថវិកាផ្ទាល់ខ្លួន .................................................................២៣

មេរៀនទី ៧ : ការពិនិត្យថវិកាផ្ទាល់ខ្លួន ................................................... ២៨

មេរៀនទី ៨ : ការរៀបចំបញ្ជីគណនេយ្យគោលសម្រាប់ការធ្វើជំនួញ ....................៣១

មេរៀនទី ៩ : តារាងលំហូរសាច់ប្រាក់សម្រាប់ការធ្វើជំនួញ ............................៣៥

មេរៀនទី ១០ : ការស្វែងយល់ពីការរៀបចំបញ្ជីគណនេយ្យ .......................... ៤២

មេរៀនទី ១១ : ការកំណត់តម្លៃទំនិញ ......................................................៤៤

មេរៀនទី ១២ : ការស្វែងយល់ពីបញ្ហាកំណត់តម្លៃ ......................................៤៤

មេរៀនទី ១៣ : ការធ្វើជំនួញ និង ថវិកាផ្ទាល់ខ្លួន ..................................... ៥២

ខ្លឹមសារសង្ខេបនៃវគ្គសិក្សាការគ្រប់គ្រងប្រាក់ ........................................... ៦១

## អារម្ភកថា

ឯកសារស្តីអំពី " **ការគ្រប់គ្រងប្រាក់** " មានបំណងជួយអ្នករៀនឱ្យទទួលបាននូវចំណេះដឹង បំណិន និងបទពិសោធន៍ក្នុងផ្នែកបំណិនជីវិតងាយៗ ទាក់ទងនឹងការគ្រប់គ្រងប្រាក់។ ប្រាក់មានតួនាទីសំខាន់ក្នុងសង្គម និងក្នុងផ្ទះរបស់យើង។ ការរៀនពីរបៀបគ្រប់គ្រងប្រាក់តាំងពីនៅវ័យក្មេង និងការផ្សារភ្ជាប់ការគ្រប់គ្រងប្រាក់ ទៅនឹងតម្រូវការទៅតាមអាទិភាពនិងគោលបំណង ដែលនឹងជួយមនុស្សវ័យក្មេងឱ្យចៀសផុតពីការប្រឈមនឹងបញ្ហា ដែលបណ្តាលមកពីភាពខ្វះការយល់ដឹងក្នុងការធ្វើជំនួញ ឬការលក់ដូរ។ យើងសង្ឃឹមថាយុវជនបច្ចុប្បន្នអាចមានការគិតដោយមានផែនការ និងមានគោលបំណងក្នុងការគ្រប់គ្រងប្រាក់ដែលគេមានដូចជា : ការឱ្យតម្លៃលើការធ្វើផែនការ ការរៀបចំថវិកា និងការធ្វើតាមគោលការណ៍សំខាន់ៗ ដើម្បីធ្វើឱ្យមុខជំនួញនោះក្លាយជាឱកាសក្នុងការអភិវឌ្ឍ។

## មេរៀនទី១ : តើខ្ញុំប្រើប្រាស់ប្រាក់យ៉ាងដូចម្តេច?

☼ **លទ្ធផលសិក្សារំពឹងទុក**

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច :

- កំណត់ការចំណាយប្រាក់នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ
- កំណត់វត្ថុដែលគ្រួសារត្រូវចំណាយប្រាក់ទិញ
- កំណត់វត្ថុដែលគ្រួសារត្រូវសន្សំប្រាក់សម្រាប់ទិញ
- ញែកបានច្បាស់លាស់ពីប្រភេទនៃការចំណាយផ្សេងៗ
- ញែកបានច្បាស់លាស់ពីវត្ថុដែលជា "ចំណង់" និង វត្ថុដែលជា " តម្រូវការ "

### ខ្ញុំ និង ប្រាក់

១. តើប្រាក់អាចឱ្យយើងធ្វើអ្វីបានខ្លះ?

___

___

___

___

២. សរសេរឈ្មោះវត្ថុ ៣ ដែលអ្នកចង់បានដោយមិនត្រូវការចំណាយប្រាក់ ។

➢ ___

➢ ___

➢ ___

៣. សរសេរឈ្មោះវត្ថុ ៣ ដែលអ្នកចង់បានដោយត្រូវការចំណាយប្រាក់ ។

➢ ___

➢ ___

➢ ___

## ការចំណាយប្រាក់ និង ការសន្សំប្រាក់

ថ្ងៃនេះ យើងពិភាក្សាគ្នាអំពីការចំណាយប្រាក់ និងការសន្សំប្រាក់។ នៅពេលយើងនិយាយពី **ការចំណាយប្រាក់** នោះយើងនិយាយអំពីផលិតផល និងសេវាកម្ម ដែលយើងត្រូវចំណាយ។ នៅពេលយើងនិយាយពី **ការសន្សំប្រាក់** នោះយើងនិយាយដោយផ្តោតទៅលើប្រាក់ដែលបានពីការលក់ផលិតផលនិងសេវាកម្ម ដែលយើងចង់រក្សាទុកសម្រាប់តម្រូវការប្រើប្រាស់នាពេលអនាគត។ ខណៈយើងមិនប្រើពាក្យ **ការសន្សំប្រាក់** នេះសំដៅទៅលើប្រាក់ដែលបានមកពីការតថ្លៃទំនិញ ឬការទិញទំនិញបានថោកនោះទេ។

១. តើគ្រួសាររបស់អ្នកចំណាយប្រាក់ទៅលើអ្វីខ្លះ?

______________________________

______________________________

______________________________

២. តើគ្រួសាររបស់អ្នកសន្សំប្រាក់សម្រាប់ធ្វើអ្វីខ្លះ?

______________________________

______________________________

______________________________

## ចំណាយថេរ

ចូរប្រាប់ពីការចំណាយ ដែលគ្រួសាររបស់អ្នកបានធ្វើ ហើយស្របទៅនឹងចំណុចទាំង២ :

(ក) ការចំណាយដែលកើតមានជារៀងរាល់ខែ (ខ) ចំនួនប្រាក់ដែលត្រូវចំណាយប្រចាំខែ

______________________________

______________________________

______________________________

ទាំងអស់នេះ ហៅថា **ចំណាយថេរ** ព្រោះការចំណាយនេះវាកើតមានជារៀងរាល់ខែ។ ការចំណាយទាំងនេះងាយស្រួលនឹងធ្វើផែនការថវិកាចំណាយ ពីព្រោះយើងដឹងពីមុខចំណាយ និងចំនួនថវិកាដែលត្រូវចំណាយជារៀងរាល់ខែ។

## ចំណាយប្រែប្រួល

ចូរប្រាប់ពីការចំណាយដែលគ្រួសាររបស់អ្នក (ក) ត្រូវការរៀងរាល់ខែ (ខ) ប៉ុន្តែមិនដឹងពិតប្រាកដពីចំនួនទឹកប្រាក់ដែលត្រូវចំណាយក្នុងខែនីមួយៗ

________________________________________

________________________________________

________________________________________

យើងអាចដឹងថាការចំណាយទាំងអស់នេះកើតមានជារៀងរាល់ខែ ប៉ុន្តែវាជា "**ចំណាយប្រែប្រួល** "។ ពិតមែនតែយើងដឹងថាវាកើតឡើងរៀងរាល់ខែ តែយើងមិនអាចកំណត់ការចំណាយពិតប្រាកដដូច ការចំណាយថេរ នោះទេ។ ការចំណាយប្រែប្រួលបែបនេះ ធ្វើឱ្យមានការលំបាកក្នុងការគ្រោងថវិកា ព្រោះយើងពុំដឹងពិតពីតម្រូវការនៃការចំណាយ។ ក្នុងករណីបែបនេះយើងគប្បីគិតពីប្រាក់ដែលយើងមាន ហើយការចំណាយរបស់យើងឱ្យស្របតាមចំនួនថវិកានោះ។

## ចំណាយដែលមិនបានគ្រោងទុក

នៅពេលខ្លះក៏មានការចំណាយដោយគ្មានការគិតទុកជាមុន។ ចូរផ្តល់ឧទាហរណ៍មួយចំនួន ស្តីពីការចំណាយបែបនេះ។

________________________________________

________________________________________

________________________________________

________________________________________

________________________________________

នៅពេលខ្លះ យើងក៏ត្រូវចំណាយប្រាក់ដោយមិនបានព្រៀងទុកទៅលើវត្ថុអ្វីមួយ។ ជាធម្មតាការចំណាយបែបនេះយើងហៅថា " **ចំណាយដែលមិនបានគ្រោងទុក** "។ ការចំណាយបែបនេះ យើងមិនអាចដឹងជាមុនបានទេ តែយើងគ្រាន់តែដឹងថាការចំណាយបែបនេះវានឹងកើតមាន ។ ដូចនេះ យើងមានការលំបាកក្នុងការគ្រោងថវិកាឱ្យត្រូវ ឬមិនអាចគ្រោងថវិកាសន្សំប្រាក់ឱ្យបានត្រូវសម្រាប់ចំណាយទៅលើអ្វីដែលកើតឡើងភ្លាមៗ ដោយមិនបានគ្រោងទុក។

## ចំណាយលើវត្ថុប្រណិត

ការចំណាយមួយបែបទៀត ហៅថាការចំណាយលើ "**វត្ថុប្រណិត**"។ ការចំណាយបែបនេះ គឺសំដៅទៅលើវត្ថុដែលយើងចង់បាន ប៉ុន្តែវាមិនមែនជាវត្ថុដែលត្រូវការចាំបាច់នោះទេ។ ចូរផ្តល់ឧទាហរណ៍មួយចំនួនស្តីពីការចំណាយបែបនេះ។

________________________________________
________________________________________
________________________________________

យើងអាចគ្រោងថវិកាមួយចំនួនជារៀងរាល់ខែ សម្រាប់ការចំណាយលើ "**វត្ថុប្រណិត** "។ ដោយសន្សំប្រាក់ក្នុងរយៈពេលយូរ។ ការចំណាយលើ "**វត្ថុប្រណិត**" គួរតែពិចារណាឱ្យបានហ្មត់ចត់ ប៉ុន្តែជាទូទៅយើងច្រើនតែចំណាយដោយមិនបានគិតគូរឡើយ។

## ប្រភេទទាំងបួននៃការចំណាយ

១. នៅក្នុងតារាងដែលនិយាយពីវត្ថុដែលគ្រួសារនីមួយៗត្រូវចំណាយ និងសន្សំប្រាក់សម្រាប់ទិញនោះ ចូរអ្នកកំណត់ប្រភេទចំណាយ : **ចំណាយថេរ ចំណាយប្រែប្រួល ចំណាយមិនបានគ្រោងទុក** និង**ចំណាយលើវត្ថុប្រណិត**? សូមសរសេរពាក្យកាត់ ដែលមាននៅក្នុងវង់ក្រចកដាក់នៅក្បែរចំណាយនីមួយៗនៅក្នុងតារាងចំណាយ

២. ហេតុអ្វីបានជាមុខចំណាយមួយចំនួនពិបាកក្នុងការធ្វើចំណាត់ថ្នាក់?

________________________________________
________________________________________
________________________________________

| និយមន័យនៃពាក្យ "ចំណង់" និង "តម្រូវការ" |
|---|

ចូរកំណត់ប្រភេទ "**ចំណង់**" ឬ ជា "**តម្រូវការ**" មុខចំណាយខាងក្រោមនេះ :

| **មុខចំណាយ** | **ចំណង់/តម្រូវការ** |
|---|---|
| ១. ម្ហូបអាហារពេលព្រឹក អាហារថ្ងៃត្រង់ ឬអាហារពេលល្ងាច | |
| ២. បាល់សម្រាប់លេងពេលសម្រាក | |
| ៣. ស្បែកជើងសម្រាប់ពាក់ទៅសាលា | |
| ៤. ស្បែកជើងសម្រាប់ពាក់ទៅចូលរួមពិធីអាពាហ៍ពិពាហ៍ | |
| ៥. ការទិញនំនៅក្រៅសាលា | |
| ៦. សៀវភៅសរសេរ និងប៊ិចសម្រាប់រៀន | |

ចូរអ្នកលើកឧទាហរណ៍មុខចំណាយ ២ ដែលទាក់ទងនឹង "**ចំណង់**" និង "**តម្រូវការ**" :

| | |
|---|---|
| **ចំណង់** | |
| **តម្រូវការ** | |

**និយមន័យ**

- **តម្រូវការ** គឺអ្វីដែលយើងត្រូវការដើម្បីរស់ មានសុខភាពល្អ និងលទ្ធភាពផ្សេងៗដូចជាមានទីកន្លែងរស់នៅ មានអាហារសម្រាប់បរិភោគ សំលៀកបំពាក់ដែលជួយការពារយើងទប់ទល់នឹងអាកាសធាតុ និងការងារ ដើម្បីឱ្យមានចំណូល ។ល។
- **ចំណង់** គឺអ្វីដែលយើងចង់បាន ប៉ុន្តែពុំមែនអ្វីដែលជាកាចាំបាច់ខានមិនបាននោះទេ។ មានន័យថាយើងអាចរស់បានដោយគ្មានវា។

## មេរៀនទី២ : តើខ្ញុំបានប្រាក់មកដោយរបៀបណា?

☼ **លទ្ធផលរំពឹងទុក**

ពេលរៀនមេរៀននេះចប់សិស្សនឹងអាច :

- កំណត់វត្ថុផ្ទាល់ខ្លួនណាមួយដែលជា "**ចំណង់**" និង "**តម្រូវការ**" ដែលអ្នកចំណាយប្រាក់
- កំណត់វិធីដែលពួកគេអាចរកប្រាក់បាន
- បង្ហាញពីភាពខុសគ្នារវាងទម្លាប់នៃការចំណាយ និងការសន្សំ
- កំណត់វិធីដែលធ្វើឱ្យខ្លួនក្លាយជាអ្នកសន្សំប្រាក់ប្រសើរជាងមុន ។

### និយមន័យនៃពាក្យ "ចំណង់" និង "តម្រូវការ"

ពាក្យទាំងពីរនេះជួនកាលមានការច្រឡំគ្នា ឬច្របូកច្របល់គ្នា មិនដឹងថាមួយណាជាតម្រូវការឬមួយណា ជាចំណង់ ។

តើអ្នកអាចប្តូរពីវត្ថុដែលជាតម្រូវការឱ្យទៅជាវត្ថុចំណង់វិញបានដែរឬទេ?

| **តម្រូវការ** | **ចំណង់** |
|---|---|
| ឧទាហរណ៍ : អាហារ | អាហារសម្រន់មុនពេលអាហារល្ងាច |
| | |
| | |
| | |
| | |
| | |

យើងត្រូវតែយល់ឱ្យច្បាស់នៅពេលយើងនិយាយពីតម្រូវការ និងចំណង់ ។ ប្រសិនបើយើងពុំបានគិតឱ្យបានល្អិតល្អន់នោះ យើងអាចប្តូរពីអ្វីដែលជាតម្រូវការទៅជាចំណង់ ។

## ខ្ញុំ និង ការប្រើប្រាស់ប្រាក់

ប្រាក់ជួយយើងឱ្យទទួលបានអ្វីដែលយើងត្រូវការ។ ជាញឹកញាប់សមាជិកគ្រួសារជាច្រើននាក់បានជួយរកប្រាក់ចូលផ្ទះ។ នៅផ្នែកនេះ យើងនិយាយពីវិធីដែលយើងរកប្រាក់ ឬទទួលបានប្រាក់ចំណូល និងទម្លាប់ក្នុងការរក្សាទុកប្រាក់នៅពេលដែលយើងមានប្រាក់។

១. តើអ្នករកប្រាក់ចំណូល ឬ ទទួលប្រាក់ចំណូលដោយវិធីណា?

______________________________

______________________________

២. ចូរបង្ហាញវិធី ២ យ៉ាងដែលអ្នកគិតថាអាចរកប្រាក់ចំណូលបាន?

➢ ______________________________

➢ ______________________________

៣. ចូរប្រាប់ឈ្មោះវត្ថុ ៣ ទៅ ៥ ប្រភេទ ដែលអ្នកត្រូវចំណាយប្រាក់ទិញ។

______________________________

______________________________

______________________________

______________________________

______________________________

៤. ចូរប្រាប់ឈ្មោះវត្ថុ ៣ ទៅ ៥ ប្រភេទ ដែលអ្នកត្រូវសន្សំប្រាក់សម្រាប់ទិញ។

______________________________

______________________________

______________________________

______________________________

______________________________

## ករណីសិក្សាស្តីពីទម្លាប់នៃការប្រើប្រាស់ប្រាក់

គ្រួសារមួយមានកូនស្រីម្នាក់ស្រស់ស្អាត។ សម្រស់របស់នាងទាក់ទាញបុរស១ជាច្រើន។ បុរសបីនាក់បានចូលមកដើម្បីសុំស្តីដណ្តឹងនាង។ ក្រុមគ្រួសារបានជួបជុំពិភាក្សាពីរឿងនេះ ដើម្បីជួយនាងក្នុងការធ្វើការសម្រេចចិត្តជ្រើសរើសបុរសម្នាក់ធ្វើជាគូគ្រង។ ពេលពិភាក្សាគេទទួលបានព័ត៌មានថា បុរសទាំងបីនាក់សុទ្ធតែជាអ្នកមានទ្រព្យសម្បត្តិ ម្នាក់១មានដល់ទៅ ៥ ម៉ឺនដុល្លារស្មើ១គ្នា។ ពួកគាត់បានប្រាក់មកដោយរបៀបខុស១គ្នា។

- បុរសទី១ជាកូនរស់នៅក្នុងគ្រួសារមធ្យម ហើយជាមនុស្សដែលមានបទពិសោធន៍ក្នុងការលេងល្បែង។ បុរសនេះពុំមានការងារធ្វើពេញម៉ោង ឬពុំមានប្រាថ្នាចង់ធ្វើការពេញម៉ោងទេ ព្រោះគេនិយាយថា គេអាចមានជីវភាពធូរធារដោយសារការលេងល្បែងស៊ីសង (មានទេពកោសល្យ)។ គេប្រាប់ក្រុមគ្រួសារគេថា ល្បែងស៊ីសងគឺជាអាជីពរបស់គេ ហើយគេមានឈ្មោះល្បីថាជាអ្នកជំនាញខាងផ្នែកលេងល្បែងស៊ីសង។
- បុរសទី២ជាកូនក្នុងគ្រួសារក្រីក្រ ប៉ុន្តែគេមានទេពកោសល្យខាងជំនួញ។ គេខិតខំធ្វើការងារ។ គេបានធ្វើការនិងសន្សំប្រាក់ហើយដាក់ទុនរកស៊ីទៀតផង ឥឡូវនេះគេក្លាយជាអ្នកធ្វើជំនួញដ៏មានជោគជ័យម្នាក់ ដោយបើកហាងលក់ និងជួសជុលកុំព្យូទ័រ។ គាត់ជាមនុស្សដែលប្រឹងប្រែងធ្វើការ ព្រមទាំងជាមនុស្សស្មោះត្រង់ និងមានទស្សនៈវិស័យសម្រាប់អនាគត។
- បុរសទី៣ជាកូនកសិករដែលមានដីធ្លីច្រើន។ គេមានសំណាង ដោយបានរកឃើញវត្ថុមានតម្លៃនៅក្នុងស្រែរបស់គេ។ គេបានលក់វត្ថុនោះបានប្រាក់យ៉ាងច្រើន។ គេសន្សំប្រាក់នេះ ព្រោះគេដឹងថា ថ្ងៃណាមួយគេនឹងរៀបការហើយមានទ្រព្យសម្បត្តិ។ គេជាអ្នកដែលប្រកាន់វិន័យ ហើយពូកែទុកដាក់ប្រាក់។ គេចាត់ទុកខ្លួនគេថាជាអ្នកមានសំណាងដោយបានរកឃើញកំណប់លាភ។

១. តើបុរសទាំងបីនៅក្នុងរឿងនេះសន្សំប្រាក់បានប៉ុន្មាន?

______________________________

២. តើបុរសទាំងបីខុសគ្នាដូចម្តេចខ្លះ?

______________________________

______________________________

៣. តើបុរសទាំងបីចំណាយប្រាក់របស់គេដូចម្តេច?

______________________________

______________________________

______________________________

៤. តើបុរសណាមួយមានផែនការសន្សំប្រាក់ល្អជាងគេ? ហេតុអ្វី?

៥. តើបុរសមួយណាដែលអ្នកគិតថាមានភាពឈ្លាសវៃក្នុងការប្រើប្រាស់ប្រាក់ជាងគេ? ហេតុអ្វី?

៦. តើបុរសមួយណាដែលអ្នកគិតថានាងគួររៀបការជាមួយ?

**ទម្លាប់ក្នុងការប្រើប្រាស់ប្រាក់របស់អ្នក**

១. តើបុរសណាម្នាក់ ដែលអ្នកចង់អនុវត្តតាមខ្លាំងជាងគេបំផុត? ហេតុអ្វី?

២. តើទម្លាប់ប្រើប្រាស់ប្រាក់ប្រភេទណាខ្លះដែលអ្នកចង់កែលំអ?

៣. ចូរសរសេរពីលក្ខណសម្បត្តិរបស់អ្នកចំណាយប្រាក់ និងអ្នកសន្សំប្រាក់ដែលឈ្លាសវៃ ។

____________________________________________

____________________________________________

____________________________________________

៤. ចូរសរសេរពីលក្ខណសម្បត្តិរបស់អ្នកចំណាយប្រាក់ និងអ្នកសន្សំប្រាក់ដែលមិនឈ្លាសវៃ ។

____________________________________________

____________________________________________

____________________________________________

# មេរៀនទី៣ : គោលបំណង តម្លៃ និង អាទិភាព

☼ **លទ្ធផលរំពឹងទុក**

ពេលរៀនមេរៀននេះចប់សិស្សនឹងអាច :

- បង្ហាញពីភាពខុសគ្នារវាងគោលបំណងរយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង
- កំណត់គោលបំណងផ្ទាល់ខ្លួន៦យ៉ាង ។

## គោលបំណង តម្លៃ និងអាទិភាព

យើងមានផ្លូវជាច្រើនដែលដឹកនាំយើងឱ្យក្លាយទៅជាអ្វីមួយ និងធ្វើអ្វីនៅពេលអនាគត ។ ទោះយ៉ាងនេះក្តី ប្រសិនបើយើងគ្រាន់តែបោះជំហានពីមួយថ្ងៃទៅមួយថ្ងៃដោយមិនបានគិតពីអនាគត នោះអនាគតរបស់យើងក៏មិនបានរៀបចំបានល្អប្រសើរដែរ ។ យើងត្រូវគិតពីអ្វីដែលយើងចង់ធ្វើ ហើយបង្កើតគោលបំណង និងយុទ្ធវិធីដើម្បីធ្វើឱ្យសម្រេចគោលបំណងនោះ បើពុំនោះទេ យើងនឹងក្លាយជាមនុស្សអសកម្មក្នុងជីវិត ។

## ករណីសិក្សារបស់តារា ដែលធ្វើជាអ្នកបម្រើ

តារាធ្លាប់ជាអ្នកបម្រើនៅក្នុងភោជនីយដ្ឋានខ្មែរមួយ ដែលស្ថិតនៅជិតកន្លែងដែលគេរស់នៅ ។ នេះគឺជាមុខរបរដំបូងរបស់តារានៅពេលរៀនចប់មធ្យមសិក្សា ។ តារារៀនពីរបៀបធ្វើការងារពីប្រធានរបស់គេ និងអ្នករួមការងារ ។ គាត់យកចិត្តទុកដាក់ពីអ្វីដែលធ្វើឱ្យភ្ញៀវពេញចិត្ត និងអ្វីដែលធ្វើឱ្យភ្ញៀវមិនសប្បាយចិត្ត ។ តារាចង់ធ្វើការនៅភោជនីយដ្ឋានមួយដែលល្អជាងនេះ ហើយស្ថិតនៅតំបន់ទេសចរ ព្រោះបានប្រាក់កម្រៃ និងប្រាក់បន្ថែមច្រើនពីភ្ញៀវ ។ នៅពេលតារាទៅដាក់ពាក្យនៅភោជនីយដ្ឋានមួយ ក្នុងបណ្តាភោជនីយដ្ឋានជាច្រើន ទើបគេដឹងថា ខ្លួនគេនៅពុំទាន់បានទទួលការបណ្តុះបណ្តាលគ្រប់គ្រាន់ និងពុំទាន់មានបទពិសោធន៍ក្នុងសេវាទទួលភ្ញៀវ ហើយក៏ពុំទាន់មានជំនាញភាសាអង់គ្លេសតាមដែលគេត្រូវការប្រើនៅទីនោះដែរ ។

១. តើជម្រើសរបស់តារាជាអ្វី?

______________________________________________

______________________________________________

______________________________________________

ថ្ងៃនេះតារាមានការខកចិត្តជាខ្លាំង នៅពេលគេបង្ហាញមុខនៅភោជនីយដ្ឋានថ្មី។ ភ្ញៀវដែលធ្លាប់មកទីនេះសួរតារាថា ហេតុអ្វីបានជាឯងស្រងូតស្រងាត់ម្ល៉េះ។ តារាបានប្រាប់ពីរឿងរ៉ាវទាំងអស់ដល់ភ្ញៀវ។ ភ្ញៀវនោះបានប្រាប់តារាកុំឱ្យអស់សង្ឃឹម ឯងពិតជាម្ចាស់ហាងឱ្យតម្លៃថ្លៃជាមិនខាន ប្រសិនបើឯងខិតខំធ្វើការឱ្យបានល្អនោះ។ ភ្ញៀវបាននិយាយទៀតថា "ឯងត្រូវទៅ (១) ទទួលការបណ្តុះបណ្តាលពីបទពិសោធន៍ក្នុងសេវាទទួលភ្ញៀវ (២) រៀនភាសាអង់គ្លេស "

២. តើអ្នកយល់ដូចម្តេចចំពោះស្ថានភាពរបស់តារា?

___

___

___

៣. តើជំនាញទាំងនេះ តារាអាចមានលទ្ធភាពរកបានដែរឬទេ?

___

___

___

នៅល្ងាចនោះតារាទៅផ្ទះ ហើយនិយាយជាមួយក្រុមគ្រួសារ។ គេធ្វើការសម្រេចចិត្តដោយគិតរកវិធី ហើយក៏ចាប់ផ្តើមធ្វើផែនការ។ គេត្រូវការការគាំទ្រពីក្រុមគ្រួសារ ដើម្បីជួយធ្វើឱ្យសម្រេចផែនការរបស់គេ។ បងប្រុសរបស់គេបាននិយាយថា គាត់មានមិត្តភក្តិម្នាក់ជាអ្នកគ្រប់គ្រងភោជនីយដ្ឋានមួយ តែវាមិនល្អដូចជាភោជនីយដ្ឋានដែលឯងបានទៅសម្ភាសនោះទេ ប៉ុន្តែកន្លែងនោះវាទាមទារអ្នកមានជំនាញល្អជាងនៅហាងដែលឯងកំពុងធ្វើបច្ចុប្បន្ន។ បងរបស់តារាបានទូរស័ព្ទទៅមិត្តគាត់។ ប៉ុន្តែមិត្តគាត់និយាយថា នៅពេលនេះគាត់មិនទាន់ត្រូវការបុគ្គលិកថ្មីនៅឡើយទេ តែគាត់ឱ្យតារាមកទីនោះ ២ ឬ ៣ ដងក្នុងមួយសប្តាហ៍ ដើម្បីចូលរៀនក្នុងវគ្គបំប៉ន និងទទួលយកបទពិសោធន៍ការងារ។ មិត្តរបស់គាត់បានឱ្យតារាធ្វើការជាមួយបុគ្គលិកដែលមានសមត្ថភាពជាងគេ ដែលអាចឱ្យតារារៀនសូត្រពីរបៀបធ្វើការងារពីបុគ្គលិកនោះ។ តារាបានធ្វើការនៅហាងមិត្តរបស់បងគាត់ ទោះជាមិនបានទទួលប្រាក់ខែក៏ដោយ។

# សៀវភៅសិស្ស

តារានៅមានបញ្ហាភាសាអង់គ្លេស ។ គេសម្រេចចិត្តសន្សំប្រាក់មួយចំនួន ដោយត្រូវផ្លាស់ប្តូរទម្លាប់នៃការចំណាយ ។ គេត្រូវការប្រាក់១៥០ដុល្លារ សម្រាប់បង់ថ្លៃវគ្គសិក្សាភាសាអង់គ្លេសក្នុងរយៈពេល៦ខែ នៅមជ្ឈមណ្ឌលភាសាអង់គ្លេសដែលនៅក្បែរនោះ ។ ដូច្នេះ គេត្រូវបង់ ២៥ ដុល្លារ ក្នុងមួយខែ ។ ចាប់តាំងពីតារាធ្វើការស្ម័គ្រចិត្តនៅហាងថ្មីមួយរយៈមក គេពុំបានចំណាយប្រាក់ទៅលើការកំសាន្តសប្បាយ គេអាចសន្សំប្រាក់បាន ព្រោះតារាគិតថា បើគេមិនចំណាយប្រាក់សម្រាប់អាហារសម្រន់ ជារៀងរាល់ថ្ងៃ ជិះកង់ទៅធ្វើការ ដោយមិនជិះម៉ូតូឌុបទៅណាមកណា ឈប់ទិញខោអាវថ្មី ព្រោះខោអាវថ្មីទាំងនេះមិនមែនជាតម្រូវការពិតប្រាកដ ព្រមទាំងរើផ្ទះទៅនៅជាមួយក្រុមគ្រួសារ ឈប់ជួលបន្ទប់ស្នាក់នៅជាមួយមិត្តភក្តិ នោះគេអាចសន្សំបានគ្រប់គ្រាន់សម្រាប់បង់ថ្លៃរៀនភាសាអង់គ្លេសរយៈពេល៦ខែ ដើម្បីអភិវឌ្ឍជំនាញភាសាអង់គ្លេសរបស់គេបន្ថែមទៀត ។

ប្រាំបីខែក្រោយមក តារាបានទៅដាក់ពាក្យជាថ្មីម្តងទៀត នៅភោជនីយដ្ឋានដែលមិនទទួលខ្លួនឱ្យធ្វើការ ។ ម្តងនេះអ្នកគ្រប់គ្រងមានការស្ងើចសរសើរ ដោយឃើញតារាមានការរីកចម្រើន ។ វគ្គបំប៉នរបស់តារាមិនទាន់ឆ្លើយតបទៅនឹងស្តង់ដាដែលភោជនីយដ្ឋាននោះចង់បាននៅឡើយទេ តែអ្នកគ្រប់គ្រងយល់ឃើញថា តារាជាមនុស្សមានឆន្ទៈចង់ធ្វើការ ។ ដូចនេះ អ្នកគ្រប់គ្រងបានឱ្យតារាធ្វើជាអ្នកយាមឡាន ប៉ុន្តែគាត់បានបញ្ជាក់ប្រាប់តារាថា បុគ្គលិកភាគច្រើនបានចាប់ផ្តើមការងារពីតួនាទីបែបនេះ ។ អ្នកគ្រប់គ្រងនោះនិយាយថា នេះមិនមែនជាតួនាទីដែលតារាឯងចង់បាននោះទេ ប៉ុន្តែនេះជាការងារដែលគាត់អាចផ្តល់ឱ្យបាន ។ តារាក៏បានយល់ព្រមទទួលការងារនោះ ។

ទោះជាយ៉ាងនេះក៏ដោយក៏តារាទទួលបានបទពិសោធន៍ និងចំណេះដឹងមួយចំនួនបន្ថែមទៀត ។ តារាកាន់តែមានភាពកក់ក្តៅជាមួយនឹងភ្ញៀវទេសចរ ហើយបានធ្វើទំនាក់ទំនងជាភាសាអង់គ្លេសទៀតផង ។ តារាខិតខំធ្វើការដោយយកចិត្តទុកដាក់ ។ ក្នុងរយៈពេល៦ខែក្រោយមក តារាត្រូវបានដំឡើងឋានៈជាអ្នករត់តុតាមការចង់បានដូចក្តីសង្ឃឹម ។

**ការពិភាក្សាលើករណីសិក្សា**

១. តើតារាមានគោលបំណងដូចម្តេច?

________________________________________

________________________________________

២. តើតារាមានបញ្ហាអ្វី?

________________________________________

________________________________________

________________________________________

# សៀវភៅសិស្ស

៣. តើនរណាជួយតារា? ជួយដោយរបៀបណា?

___

___

___

___

៤. តើតារាបានដោះស្រាយបញ្ហាដោយរបៀបណា?

___

___

___

៥. ប្រសិនបើអ្នកជាតារា តើអ្នកគិតដូចម្ដេច?

___

___

___

___

___

៦. តើតារាបានបញ្ចប់គោលដៅសម្រាប់ជីវិតរបស់គាត់ហើយឬនៅ?

___

___

___

## គោលដៅរបស់អ្នក ឬ គោលដៅអាជីព

តារាបង្កើតគោលបំណងមួយ ដែលជាមានសេចក្តីប្រាថ្នាខ្ពស់ហើយវាក៏ជាគោលដៅសម្រាប់អនាគតផងដែរ ។ យើងអាចបង្កើតគោលដៅប្រចាំថ្ងៃ គោលដៅសម្រាប់សប្តាហ៍ក្រោយ ខែក្រោយ និងឆ្នាំក្រោយ ។ គោលដៅទាំងនេះ អាចទាក់ទងទៅនឹងមុខរបរ ការសិក្សា ទំនាក់ទំនងសង្គម ការអភិវឌ្ឍផ្ទាល់ខ្លួន និងផ្នែកផ្សេងៗ ។ ឥឡូវនេះ យើងសាកល្បងបង្កើតគោលដៅមួយចំនួនសម្រាប់ខ្លួនយើង ។

១. កំណត់គោលដៅរយៈពេលខ្លី (១-៤សប្តាហ៍) ២ចំណុច

________________________________________

________________________________________

________________________________________

________________________________________

________________________________________

២. កំណត់គោលដៅរយៈពេលមធ្យម(២-១១ខែ) ២ចំណុច

________________________________________

________________________________________

________________________________________

________________________________________

________________________________________

៣. កំណត់គោលដៅរយៈពេលវែង (១ឆ្នាំ ឬលើសពី១ឆ្នាំ) ២ចំណុច

________________________________________

________________________________________

________________________________________

________________________________________

________________________________________

៤. ឥឡូវអ្នកមានគោលដៅ ៦ តើគោលដៅណាខ្លះដែលសំខាន់ជាងគេសម្រាប់អ្នក។ លេខ ១ សម្រាប់គោលដៅដែលសំខាន់ជាងគេ និងដាក់លេខ៦ សម្រាប់គោលដៅណាដែលមិនសំខាន់សោះ។

## ការធ្វើផែនការដើម្បីធ្វើឱ្យសម្រេចគោលដៅ

យើងពិនិត្យមើលឱ្យបានស៊ីជំរៅទៅលើគោលដៅជាអាទិភាព២ដំបូងដែលមាននៅក្នុងតារាងអាទិភាពរបស់យើង។ ដើម្បីយល់ឱ្យច្បាស់ពីគោលដៅជាអាទិភាពចំបងទាំង២ ចូរសាកល្បងឆ្លើយនឹងសំណួរទាំងនេះសម្រាប់គោលដៅមួយម្តងៗដោយសរសេរចម្លើយនៅក្នុងសៀវភៅកំណត់ត្រា :

១. តើយើងត្រូវមានការគាំទ្រ ឬ សញ្ញាប័ត្រអ្វីខ្លះ ដើម្បីសម្រេចគោលដៅនេះ?
២. តើយើងអាចធ្វើអ្វីខ្លះ ដើម្បីធ្វើឱ្យសម្រេចគោលដៅនេះ?
៣. តើធនធានអ្វីខ្លះដែលយើងត្រូវការដើម្បីធ្វើឱ្យសម្រេចគោលដៅនេះ?
៤. តើយើងអាចកំណត់វិធីមួយចំនួនដែលអាចសន្សំប្រាក់ ដើម្បីធ្វើឱ្យសម្រេចគោលដៅនេះបានឬទេ?
៥. តើយើងត្រូវដើរតាមជំហានអ្វីខ្លះទៀត ដើម្បីធ្វើឱ្យសម្រេចគោលដៅនេះ?
៦. តើអ្នកណាអាចជួយផ្តល់ព័ត៌មានឱ្យយើង ឬជួយយើងក្នុងការធ្វើផែនការ ដើម្បីធ្វើឱ្យសម្រេចគោលដៅនេះ?
៧. តើមានចំណុចអ្វីខ្លះដែលយើងអាចរៀនសូត្រពីតារា ដើម្បីពង្រឹងផែនការ?

## មេរៀនទី៤ : ទម្លាប់នៃការចំណាយប្រាក់

☼ **លទ្ធផលសិក្សារំពឹងទុក**

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច :

- កត់ត្រាពីតម្រូវការ និង ជំហាន ក្នុងការសម្រេចគោលដៅខាងលើ
- បង្ហាញពីលក្ខណសម្បត្តិនៃទម្លាប់ចំណាយប្រាក់ដែលឈ្លាសវៃ មិនឈ្លាសវៃ (ល្អ និងមិនល្អ) ដល់អ្នកណាម្នាក់ដែលចង់សន្សំប្រាក់ ។

### ការសម្តែងតួពីទម្លាប់នៃការចំណាយប្រាក់

១. នៅពេលដើរតាមផ្លូវ វណ្ណៈ រើសបានក្រដាសប្រាក់ ៥ ម៉ឺនរៀលមួយសន្លឹក ។ គាត់សប្បាយចិត្តណាស់ ព្រោះគាត់កំពុងតែព្យាយាមសន្សំប្រាក់ដើម្បីទិញនាឡិកាដៃមួយ ។ នៅពេលវណ្ណៈនិយាយប្រាប់សុផល ពីសំណាងរបស់គាត់ ដែលរើសបានប្រាក់នេះធ្វើឱ្យមិត្តគាត់សើច ។

២ ឆ្នាំនេះសីហាបានអានសៀវភៅច្រើន ។ គាត់គិតរកទិញវ៉ែនតាសម្រាប់មើលអក្សរ ដើម្បីកុំឱ្យភ្នែកគាត់នឿយហត់ ។ គាត់ឃើញហាងមួយមានលក់វ៉ែនតាដែលមានតម្លៃថោកជាងហាងដទៃ ។ គាត់នៅឆ្ងល់អំពីគុណភាពរបស់វា តែគាត់គិតថា បើគាត់ទិញវាក្នុងតម្លៃថោកនោះ គាត់នឹងអាចសល់ប្រាក់ខ្លះដើម្បីទៅជួបមិត្តភក្តិនៅហាងកាហ្វេ ។

៣ រៀងរាល់ថ្ងៃ ពេលចេញពីសាលា មិត្តភក្តិសុធាតែងឃាត់សុធាមិនឱ្យទៅលេងបៀ ។ សុធាបានសន្សំប្រាក់ដែលចំណេញពីការលក់នំប៉័ង និងកម្រៃដែលបានមកពីការធ្វើការងារផ្ទះឱ្យម្តាយមីង ។ ប្រាក់ដែលគេសន្សំមិនទាន់បានគ្រប់ចំនួនសម្រាប់ទិញកង់ថ្មីដែលគេចង់បាននៅឡើយ ។ ដូចនេះ គេក៏សម្រេចចិត្តលេងល្បែងជាមួយមិត្តភក្តិ ។

៤ ឪពុកមាស៊ីផុងមកលេងផ្ទះស៊ីផុង ហើយបានឱ្យប្រាក់គេ ២៥ ០០០ រៀល ។ ស៊ីផុនកំពុងគិត ថាតើគេត្រូវយកប្រាក់នេះទៅទិញអ្វី ។ គេព្យាយាមគិតពិចារណាពីជម្រើសដែលគេត្រូវចំណាយប្រាក់ ។

# សៀវភៅសិស្ស

ឱ្យសិស្សរៀបចំការសម្តែងតួ ដែលបង្ហាញពីការសម្រេចចិត្តទាក់ទងទៅនឹងរបៀបចំណាយប្រាក់។ គ្រូលើកឧទាហរណ៍២សម្រាប់ការសម្តែងតួ (១) បង្ហាញពីឥរិយាបថអវិជ្ជមាននៃអ្នកចំណាយប្រាក់ដែលមិនឈ្លាសវៃ ឬមិនល្អ។ (២) បង្ហាញពីឥរិយាបថវិជ្ជមាននៃអ្នកចំណាយប្រាក់ដែលឈ្លាសវៃ ឬ ល្អ។

| ការសម្គាល់ពីលក្ខណៈអ្នកចំណាយប្រាក់ដែលល្អ និង មិនល្អ |
|---|

១. ចូរសរសេរពីលក្ខណសម្បត្តិ ៣ យ៉ាងរបស់អ្នកចំណាយប្រាក់ដែលមិនឈ្លាសវៃ ឬ មិនល្អ។

___

___

___

២. ចូរសរសេរពីលក្ខណសម្បត្តិ ៣ យ៉ាងរបស់អ្នកចំណាយប្រាក់ដែលឈ្លាសវៃ ឬ ល្អ។

___

___

___

៣. ចូរអ្នកបង្ហាញអំពីស្ថានភាពដែលអ្នកធ្លាប់ជាអ្នកចំណាយប្រាក់ដែលឈ្លាសវៃ ឬ អ្នកចំណាយប្រាក់ដែលមិនឈ្លាសវៃ?

___

___

___

___

___

___

## មេរៀនទី ៥ : ការបង្កើតសៀវភៅកត់ត្រាការចំណាយប្រចាំថ្ងៃ

☼ **លទ្ធផលសិក្សារំពឹងទុក**

ពេលរៀនមេរៀននេះចប់សិស្សនឹងអាច :

- ធ្វើសៀវភៅកត់ត្រាចំណាយប្រចាំថ្ងៃ ។

### សៀវភៅកំណត់ត្រាចំណាយប្រចាំថ្ងៃ

ដើម្បីធ្វើខ្លួនជាអ្នកចំណាយប្រាក់ដែលឈ្លាសវៃ និងក្លាយខ្លួនជាអ្នកសន្សំប្រាក់ដ៏ល្អ យើងត្រូវយកចិត្តទុកដាក់ពីរបៀបចំណាយប្រាក់ និងគិតឱ្យបានល្អិតល្អន់ពីវិធីចំណាយដោយយើងធ្វើការប្រៀបធៀបរវាង ការចំណាយសម្រាប់ចំណង និងគោលដៅនៃការចំណាយ ។ ឥឡូវនេះយើងត្រូវសាកល្បងប្រើតារាងកំណត់ត្រាចំណាយប្រចាំថ្ងៃផ្ទាល់ខ្លួន ដើម្បីពិនិត្យមើលការចំណាយរបស់យើងដែលកើតមានក្នុង ២ ឬ ៣ សប្ដាហ៍ក្រោយនេះ ។

**តារាងកត់ត្រាចំណាយប្រចាំថ្ងៃផ្ទាល់ខ្លួន**

| កាលបរិច្ឆេទ | ប្រភេទទំនិញ | តម្លៃ | | | |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | **ចំនួនសរុបប្រចាំសប្ដាហ៍:** | $ | | | |

១. ឥឡូវចូរសង្កេតមើលតារាងនេះ ជួរទី(១) ប្រាប់ពីកាលបរិច្ឆេទនៃការទិញទំនិញ (ឬ ការចំណាយ) ជួរទី(២) ប្រាប់ពីមុខទំនិញដែលអ្នកបានទិញ (ការទិញទំនិញ ឬ ការប្រើសេវាកម្ម) និងជួរទី(៣) ប្រាប់ពីតម្លៃទំនិញ ។

| កាលបរិច្ឆេទ | ប្រភេទទំនិញ | តម្លៃ |
|---|---|---|
| | | |

**អ្នកគួរតែសរសេរនៅក្នុងសៀវភៅកំណត់ត្រាចំណាយប្រចាំថ្ងៃរបស់អ្នក គ្រប់ពេលដែលអ្នកបានចំណាយ**

២. ចូរពិនិត្យមើលប្រអប់ ២ បន្ទាប់ដែលមានដាក់ឈ្មោះថា "**ចំណង់**"និង "**តម្រូវការ**" ។ ម្តងនេះអ្នកត្រូវ សម្រេចចិត្ត ថាតើការចំណាយនីមួយៗរបស់អ្នកវាឆ្លើយតបទៅនឹង "**ចំណង់**" ឬ "**តម្រូវការ**" ហើយសរសេរ សញ្ញាខ្វែង “X” នៅក្នុងប្រអប់ឱ្យបានត្រឹមត្រូវ ។

| កាលបរិច្ឆេទ | ប្រភេទទំនិញ | តម្លៃ |
|---|---|---|
| | | |

| ចំណង់ | តម្រូវការ |
|---|---|
| | |

៣. ចូរពិនិត្យប្រអប់ដែលដាក់ឈ្មោះថា "**គោលបំណង**" ។ អ្នកគួរពិនិត្យមើលឡើងវិញលើគោលដៅរបស់អ្នកដែលបាន កំណត់កាលពីមុន ហើយធ្វើការសម្រេចចិត្ត ថាតើការចំណាយនីមួយៗរបស់អ្នកវាឆ្លើយតបទៅនឹងគោលដៅរបស់ អ្នក ឬមិនឆ្លើយតប។ ចូរសរសេរពាក្យ "**បាស/បាទ**" ប្រសិនបើការចំណាយនោះវាជួយគាំទ្រដល់ការធ្វើឱ្យ សម្រេចគោលបំណងដែលបានកំណត់ ឬ "**ទេ**" ប្រសិនបើការចំណាយនោះវាមិនជួយគាំទ្រដល់ការធ្វើឱ្យសម្រេច គោលបំណងដែលបានកំណត់ ។

| កាលបរិច្ឆេទ | ប្រភេទទំនិញ | តម្លៃ |
|---|---|---|
| | | |

| ចំណង់ | តម្រូវការ |
|---|---|
| | |

| គោលបំណង |
|---|
| |

៤. មូលហេតុដែលយើងធ្វើការកត់ត្រាការចំណាយប្រចាំថ្ងៃគឺដើម្បីធ្វើឱ្យយើង :

- អាចចងចាំបានពីអ្វីដែលយើងបានចំណាយប្រាក់
- អាចវិភាគបានទៅលើលក្ខណៈនៃការចំណាយ
- ដឹងថាការចំណាយប្រាក់ភាគច្រើនទៅលើវត្ថុដែលជាតម្រូវការចាំបាច់ ជាងចំណាយប្រាក់ឥតប្រយោជន៍ទៅលើ វត្ថុដែលជាចំណង់ ។
- ដឹងថាតើយើងចំណាយប្រាក់ប៉ុន្មានទាក់ទងនឹងគោលដៅរបស់យើង ហើយការចំណាយប្រាក់នោះសម្រាប់គោល ដៅរយៈពេលខ្លី ឬ រយៈពេលវែង
- មានកំណត់ត្រា ដែលអាចធ្វើឱ្យយើងកំណត់បានពីរបៀបកាត់បន្ថយការចំណាយ និងធ្វើការសន្សំប្រាក់ឱ្យបាន ច្រើនសម្រាប់ការទិញទំនិញ ការប្រើសេវាកម្មដែលមានសារប្រយោជន៍ ចំពោះអ្នកក្នុងការធ្វើផែនការគោលដៅ របស់យើងដែលបានកំណត់ក្នុងរយៈពេលវែង ។

៥. ចូរអ្នកប្រាប់ពីមូលហេតុផ្សេងទៀតនៃការប្រើប្រាស់សៀវភៅកំណត់ត្រាចំណាយប្រចាំថ្ងៃ។

## ការអនុវត្តប្រើប្រាស់សៀវភៅកំណត់ត្រាចំណាយប្រចាំថ្ងៃ

ក្រោយពីអ្នកកត់ត្រាកំណត់ត្រាការចំណាយប្រចាំថ្ងៃរបស់អ្នកកាលពីសប្តាហ៍មុននៅក្នុងសៀវភៅ ចូរសរសេរចម្លើយចំពោះសំណួរដូចតទៅ :

១. តើអ្នកបានរៀនអ្វីខ្លះពីទម្លាប់នៃការចំណាយប្រាក់របស់អ្នក ហើយ តើការចំណាយប្រាក់នោះទាក់ទងនឹង " **ចំណង់** " " **តម្រូវការ** " និង " **គោលដៅ** " របស់អ្នក?

២. តើអ្នកគិតថាខ្លួនអ្នកជាអ្នកចំណាយប្រាក់ដែលឈ្លាសវៃដែរឬទេ? ចូរពន្យល់។

៣. តើអ្នកគិតថាអ្នកនឹងអាចចំណាយប្រាក់ដោយឈ្លាសវៃ ដែរឬទេ? ចូរពន្យល់។

៤. ចូរត្រឡប់ទៅមើលតារាងកំណត់ត្រាចំណាយប្រចាំថ្ងៃរបស់អ្នក ហើយ ដាក់ឈ្មោះលើមុខចំណាយនីមួយៗរបស់អ្នកដោយសរសេរពាក្យ "**ចំណាយថេរ**" "**ចំណាយប្រែប្រួល**" "ចំណាយដែលមិនបានគ្រោងទុក" ឬ "**ចំណាយលើវត្ថុប្រណិត**" ។

# មេរៀនទី៦ : ថវិកាផ្ទាល់ខ្លួន

☼ **លទ្ធផលសិក្សារំពឹងទុក**

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច :

- វិភាគអាកប្បកិរិយាក្នុងការចំណាយ
- កំណត់ជម្រើសផ្សេងៗក្នុងការចំណាយ
- គ្រោងថវិកាប្រចាំសប្តាហ៍បែបងាយៗ
- ពិនិត្យតាមដានការចំណាយ
- កំណត់តម្លៃ ឬសារប្រយោជន៍ នៃការគ្រោងថវិកា
- បង្ហាញថាថវិកាអាចមានការប្រែប្រួលនៅពេលខ្លះ ។

## ការបង្កើតតារាងគ្រោងថវិកាផ្ទាល់ខ្លួន

១. ហេតុអ្វីបានជាយើងចាំបាច់ត្រូវបង្កើតតារាងគ្រោងថវិកា?

_______________________________________________

_______________________________________________

_______________________________________________

នេះជាឧទាហរណ៍គំរូតារាងគ្រោងថវិកាមូលដ្ឋាន ។ នៅពេលបង្កើតតារាងគ្រោងថវិកាផ្ទាល់ខ្លួន អ្នកគប្បីបង្កើតជួរប្រអប់ឱ្យបានច្រើនតាមដែលអ្នកត្រូវការ ( ប្រភេទចំណាយនីមួយៗ) ។

**តារាងគ្រោងថវិកាផ្ទាល់ខ្លួន**

| ប្រាក់ចំណូល និង ចំណាយ | ថវិកា | ចំនួនជាក់ស្តែង | ភាពខុសគ្នា |
|---|---|---|---|
| **ចំណូលដែលរំពឹងទុក** | | | |
| ប្រាក់ឧបត្ថម្ភ | | | |
| ប្រាក់ធ្វើការងារតាមផ្ទះ | | | |
| ប្រាក់ខែ | | | |
| ចំណូលប្រចាំសប្តាហ៍សរុប | | | |

| | | | |
|---|---|---|---|
| **ចំណាយដែលរំពឹងទុក** | | | |
| ចំណាយថេរ | | | |
| ចំណាយប្រែប្រួល | | | |
| ចំណាយផ្សេងៗទៀតដែលអាចមាន | | | |
| **ចំណាយប្រចាំសប្តាហ៍សរុប** | | | |
| **ប្រាក់សន្សំសរុប (ចំណូលដកចំណាយ)** | | | |

២. ចូររៀបរាប់ពីវិធីមួយចំនួនដែលអ្នកទទួលបានប្រាក់។

___

___

___

៣. ចូររៀបរាប់ពីវិធីមួយចំនួនដែលអ្នកអាចរកប្រាក់បាន។

___

___

___

៤. កំណត់ការចំណាយមួយចំនួនដែលមាននៅក្នុងសៀវភៅកំណត់ត្រាចំណាយប្រចាំថ្ងៃរបស់អ្នក ដោយដាក់ឱ្យត្រូវតាមប្រភេទចំណាយខាងក្រោម ។

| |
|---|
| ចំណាយថេរ : |
| ចំណាយប្រែប្រួល : |
| ចំណាយផ្សេងៗ(ចំណាយដែលមិនបានគ្រោងទុក ឬ ចំណាយលើវត្ថុប្រណិត) : |

៥. តើប្រភេទចំណាយអ្វីខ្លះ ដែលអ្នកត្រូវដាក់បញ្ចូលទៅក្នុងតារាងគ្រោងថវិកាចំណាយរបស់អ្នក ?

[ឧទាហរណ៍ : ថ្លៃជិះម៉ូតូកង់បី ម៉ូតូឌុប ថ្លៃសាំង ថ្លៃសំបកកង់ម៉ូតូ តើជាប្រភេទចំណាយអ្វី ? ចំពោះការចំណាយបែបនេះ អ្នកគួរដាក់ឈ្មោះថា "**ការចំណាយលើមធ្យោបាយធ្វើដំណើរ** " ។]

______________________________

______________________________

______________________________

______________________________

៦. ដើម្បីរៀបចំតារាងគ្រោងថវិកាយើងត្រូវ :

- ពិនិត្យមើលសៀវភៅកំណត់ត្រាចំណាយប្រចាំថ្ងៃរបស់អ្នកឡើងវិញ និង បង្កើតប្រភេទចំណាយទូទៅសម្រាប់តារាងគ្រោងថវិការបស់អ្នក
- កំណត់ប្រភេទចំណាយឱ្យបានត្រឹមត្រូវ
- គូសតារាងគ្រោងថវិកា ហើយ បញ្ចូលប្រភេទចំណាយទាំងនេះទៅក្នុងតារាងនោះ
- សូមកុំបារម្ភប្រសិនបើអ្នកគ្មានមុខចំណាយសម្រាប់ប្រភេទចំណាយនីមួយៗ ហើយក៏មិនចាំបាច់ដាក់បញ្ចូលគ្រប់ ប្រភេទចំណាយទាំងអស់ទៅក្នុងតារាង គ្រោងថវិការបស់អ្នកដែរ

**សូមកត់សម្គាល់ថា**

ប្រភេទថវិកាផ្ទាល់ខ្លួនរបស់អ្នក និងចំនួនថវិកាដែលអ្នកមានគឺវាពិតជាមិនដូចគ្នាទៅនឹងតារាងគ្រោងថវិការបស់មិត្តអ្នកឡើយ ។ តារាងគ្រោងថវិការបស់អ្នកខុសពីតារាងគ្រោងថវិការបស់មិត្តអ្នក ។ តារាងគ្រោងថវិកាទាំងនេះជាការឆ្លុះបញ្ចាំងឱ្យឃើញពីប្រាក់ចំណូល និងទម្លាប់ចំណាយប្រាក់ផ្ទាល់ខ្លួនរបស់យើង ។ តារាងគ្រោងថវិកាទាំងនេះមិនតម្រូវឱ្យដូចគ្នាទៅនឹងតារាងគ្រោងថវិការបស់មិត្តអ្នកឡើយ ។

## របៀបគណនារកចំនួនថវិកា

ដើម្បីរៀបចំថវិការបស់អ្នកជាដំបូងត្រូវចាប់ផ្ដើមជាមួយនឹងជួរ "**ថវិកា**"។ ចំណែកព័តិមាននៅក្នុងជួរ "**ចំនួនជាក់ស្ដែង**" គឺអ្នកត្រូវបំពេញនៅចុងបញ្ចប់នៃសកម្មភាពគ្រោងថវិការបស់អ្នក។

ដើម្បីស្វែងយល់ពីលំនាំនៃការបំពេញតារាងគ្រោងថវិការបស់អ្នក យើងត្រូវពិនិត្យមើលលើចំនួនថវិកាប្រចាំសប្ដាហ៍ជាមុនសិន។ មនុស្សមួយចំនួនគេគ្រោងថវិកាប្រចាំខែ ហើយអ្នកផ្សេងទៀតគេគ្រោងថវិកាប្រចាំឆ្នាំ។ នេះមានន័យថា នៅចុងសប្ដាហ៍យើងគួរតែពិនិត្យមើលតារាងគ្រោងថវិកា ហើយបំពេញព័តិមាននៅត្រង់ប្រអប់ **ចំនួនជាក់ស្ដែង**

១. ដោយផ្អែកលើបទពិសោធន៍កន្លងមក អ្នកត្រូវបំពេញព័តិមាននៅក្នុងតារាងគ្រោងថវិការបស់អ្នកនូវចំនួនទឹកប្រាក់ដែលអ្នកគិតថាជាប្រាក់ចំណូលរបស់អ្នកនៅសប្ដាហ៍ក្រោយ។

២. បូកសរុបចំនួនប្រាក់ចំណូលដែលរំពឹងទុកសម្រាប់សប្ដាហ៍នីមួយៗ។

៣. សម្រាប់ប្រភេទចំណាយនីមួយៗ អ្នកគួរពិនិត្យមើលនៅក្នុងសៀវភៅកំណត់ត្រាចំណាយប្រចាំថ្ងៃរបស់អ្នកឡើងវិញ។

៤. ចូរគិតអំពីការចំណាយផ្សេងៗដែលអ្នកអាចមាននៅក្នុងសប្ដាហ៍នេះ។

៥. ដោយផ្អែកលើចំនួនទាំងនេះ ចូរធ្វើការប៉ាន់ស្មានពីចំនួនប្រាក់ដែលនឹងត្រូវចំណាយសម្រាប់ប្រភេទនីមួយៗ ដែលអ្នកបានរាយឈ្មោះនៅក្នុងតារាងគ្រោងថវិការបស់អ្នក។

៦. ចូរសរសេរពីចំនួនទឹកប្រាក់ដែលជាការប៉ាន់ស្មានទាំងនេះនៅក្នុងជួរ "ថវិកា" (ការប៉ាន់ស្មានដែលល្អ គឺអាស្រ័យទៅលើបទពិសោធន៍កន្លងមករបស់អ្នក) សម្រាប់ចំនួនទឹកប្រាក់ដែលអ្នកត្រូវការតាមប្រភេទនីមួយៗ សម្រាប់សប្ដាហ៍ក្រោយ។

៧. សូមគិតឱ្យបានច្បាស់មុននឹងអ្នកសម្រេចចិត្តបន្តទៅមុខទៀត ៖ តើអ្នកមានបាត់នូវប្រភេទចំណាយណាមួយដែរឬទេ? ប្រសិនបើមានបាត់ សូមដាក់បន្ថែមប្រភេទទាំងនេះ។ ប្រសិនបើ ពុំមានបាត់ទេ សូមបន្តទៅជំហានបន្ទាប់ទៀត។

៨. បូកសរុបចំនួនថវិកាទាំងអស់របស់អ្នក ហើយសរសេរចំនួនប្រាក់សរុបនេះនៅក្នុងជួរ "**ថវិកា**" ត្រង់ "**ការចំណាយសរុបប្រចាំខែ**"។

៩. ចំនួនប្រាក់ចំណាយសរុបរបស់អ្នក <u>មិនគួរ</u> មានចំនួនច្រើនជាងប្រាក់ចំណូលសរុបឡើយ។ ចូរកាត់បន្ថយការចំណាយរបស់អ្នក ប្រសិនបើអ្នកមានការចំណាយច្រើនជាងប្រាក់ចំណូល។

១០. រក្សាប្រអប់ក្នុងជួរ "**ចំនួនជាក់ស្ដែង**" និង "**ភាពខុសគ្នា**" ឱ្យនៅទំនេរ។ អ្នកនឹងត្រូវបំពេញព័តិមាននៅក្នុងប្រអប់ទាំងនេះនៅសប្ដាហ៍ក្រោយ។

១១. សរសេរបំពេញចំនួនទឹកប្រាក់ ដែលអ្នកត្រូវសន្សំនៅក្នុងប្រអប់ " **ប្រាក់សន្សំសរុប** " ដោយធ្វើការគណនា ចំនួនប្រាក់ចំណូលសរុបដកជាមួយនឹងប្រាក់ចំណាយសរុប ។ ចំនួនទឹកប្រាក់ដែលគណនានេះមិនអាចចេញជាសញ្ញាអវិជ្ជមាន ហើយវាក៏មិនមែនជាប្រាក់ដែលត្រូវសន្សំដែរ ។

| |
|---|
| សម្រាប់សប្តាហ៍ក្រោយ ចូរសរសេរនៅក្នុងសៀវភៅកំណត់ត្រាចំណាយប្រចាំថ្ងៃរបស់អ្នក ។<br>អ្នកនឹងត្រូវប្រើព័ត៌មាននេះយកទៅបំពេញនៅក្នុងតារាងគ្រោងថវិកាផ្ទាល់ខ្លួនរបស់អ្នក! |

## មេរៀនទី៧ ៖ ការពិនិត្យថវិកាផ្ទាល់ខ្លួន

☼ **លទ្ធផលសិក្សារំពឹងទុក**

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច ៖

- វិភាគលើឥរិយាបថក្នុងការចំណាយ
- កំណត់ជម្រើសផ្សេងដែលអាចមានទំនាក់ទំនងជាមួយការចំណាយ
- ពិនិត្យ និង កែសម្រួលឡើងវិញលើថវិកាចំណាយប្រចាំសប្ដាហ៍
- ត្រួតពិនិត្យមើលការចំណាយ
- កំណត់ថវិកាដែលមាន
- បង្កើតថវិកាប្រចាំសប្ដាហ៍ ។

### ការគណនាចំនួនប្រាក់ចំណាយពិតរបស់អ្នកប្រចាំសប្ដាហ៍

១. តើអ្នកយល់ឃើញដូចម្ដេចចំពោះព័ត៌មានដែលសរសេរនៅជួរ "**ចំនួនជាក់ស្ដែង**" ក្នុងតារាងគ្រោងថវិកា?

___

___

___

២. ដើម្បីបំពេញព័ត៌មានក្នុងប្រអប់នៃតារាងអ្នកត្រូវអនុវត្តតាមជំហានដូចតទៅ ៖

- បញ្ចូលព័ត៌មានពីចំនួនប្រាក់ចំណូលជាក់ស្ដែង ដែលអ្នកទទួលបានទៅក្នុងប្រភេទចំណាយដែលអ្នកបានកំណត់ ។
- ផ្ទេរព័ត៌មានពីសៀវភៅកំណត់ត្រាចំណាយប្រចាំថ្ងៃរបស់អ្នកចូលទៅក្នុងតារាងគ្រោងថវិកាផ្ទាល់ខ្លួនរបស់អ្នក ។ ដោយត្រូវ ៖
  - o កំណត់ថាតើប្រភេទចំណាយនីមួយៗត្រូវយកទៅដាក់ត្រង់កន្លែងណាក្នុងតារាងគ្រោងថវិកា ។
  - o ធ្វើការបូកសរុបរាល់ការចំណាយសម្រាប់មុខចំណាយនីមួយៗឱ្យត្រូវគ្នានឹងប្រភេទចំណាយ ។
  - o សរសេរចំនួនសរុបដែលបានគណនារួចចូលទៅក្នុងជួរ "**ចំនួនជាក់ស្ដែង**" ឱ្យបានត្រឹមត្រូវសម្រាប់ប្រភេទនីមួយៗ ។

o បូកសរុបការចំណាយទាំងអស់បញ្ចូលគ្នា រួចសរសេរចំនួនសរុបនេះទៅក្នុងជួរ " **ចំនួនជាក់ស្តែង**" សម្រាប់ជួរ " **ការចំណាយសរុបប្រចាំសប្តាហ៍** " ។

៣. ដើម្បីគណនាចំនួនប្រាក់សន្សំសរុបជាក់ស្តែង ត្រូវគណនាតាមវិធីដូចខាងក្រោម:

| **ប្រាក់ចំណូលសរុបជាក់ស្តែង - ប្រាក់ចំណាយសរុបជាក់ស្តែង = ចំនួនប្រាក់សន្សំសរុបជាក់ស្តែង** |
|---|

**កំណត់សម្គាល់ :** ប្រសិនបើចំនួនប្រាក់ចំណូលជាក់ស្តែងច្រើនជាងប្រាក់ចំណាយជាក់ស្តែងនោះ ពេលនោះគេមានចំនួនប្រាក់សន្សំជាក់ស្តែង ។

| ការគណនា "ភាពខុសគ្នា " នៅលើតារាងថវិការបស់អ្នក |
|---|

១. តើអ្នកយល់ឃើញដូចម្តេចចំពោះព័ត៌មានដែលសរសេរនៅក្នុងជួរ " **ភាពខុសគ្នា** " ក្នុងតារាងគ្រោងថវិកា?

________________________________________

________________________________________

________________________________________

- យើងពិនិត្យមើលភាពខុសគ្នារវាងប្រាក់ចំណូល និងប្រាក់ចំណាយ ។
- យើងចង់ឱ្យប្រាក់ចំណូលជាក់ស្តែងខ្ពស់ជាងចំនួនថវិកាដែលមាន ។
- យើងចង់ឱ្យចំនួនជាក់ស្តែងទាបជាងចំនួនថវិកាដែលមាន ។
- តាមរូមមន្តយើងតែងចង់បានប្រាក់ចំណូលមានចំនួនខ្ពស់ជាងការចំណាយ ។

យើងប្រើវិធីគណនាផ្សេងៗគ្នាសម្រាប់គណនាពី **ភាពខុសគ្នា**

**ប្រាក់ចំណូល**

- សម្រាប់ប្រាក់ចំណូលដែលយើងចង់ឱ្យមានចំនួនជាក់ស្តែងខ្ពស់ជាង ចំនួនថវិកាពិតដែលមាន នោះយើងត្រូវប្រើវិធីគណនាដូចខាងងក្រោម :

| **ចំនួនប្រាក់ចំណូលជាក់ស្តែង — ចំនួនថវិកាដែលមាន = ចំនួនប្រាក់ខុសគ្នា** |
|---|

- ការប្រើវិធីនេះ ប្រសិនបើថវិកាជាក់ស្តែងខ្ពស់ជាង ថវិកាដែលមាន ដូចនេះការគណនាបានបង្ហាញច្បាស់ពីលទ្ធផលវិជ្ជមាន ។

**ប្រាក់ចំណាយ**

➢ សម្រាប់ប្រាក់ចំណាយដែលយើងចង់ឱ្យមានចំនួនចំណាយជាក់ស្តែងទាបជាង ចំនួនថវិកាដែលយើងមាន នោះធ្វើឱ្យយើងអាចសន្សំប្រាក់បានច្រើន ។ ដូច្នេះយើងអាចប្រើវិធីគណនាដូចខាងក្រោម :

| **ចំនួនប្រាក់ចំណាយដែលមាន - ចំនួនប្រាក់ចំណាយជាក់ស្តែង = ចំនួនប្រាក់ចំណាយខុសគ្នា** |
|---|

➢ ការប្រើវិធីនេះ ប្រសិនបើថវិកាចំណាយដែលមានខ្ពស់ជាងចំនួនប្រាក់ចំណាយជាក់ស្តែង ។ ដូចនេះ ការគណនាបានបង្ហាញច្បាស់ពីលទ្ធផលវិជ្ជមាន ។

២. ចូរពិនិត្យមើលទឹកប្រាក់ខុសគ្នារបស់អ្នក រួចឆ្លើយនឹងសំណួរខាងក្រោម :

✌ តើអ្នករកបាន "**ប្រាក់ចំណូល**" ច្រើនជាង តិចជាង ឬ ដូចគ្នាទៅនឹងផែនការដែលអ្នកកំណត់?

---

✌ តើអ្នកបាន "**ចំណាយប្រាក់**" ច្រើនជាង តិចជាង ឬ ដូចគ្នានឹងទៅផែនការដែលអ្នកកំណត់?

---

✌ ប្រសិនបើអ្នកបានពិនិត្យមើលលើថវិការបស់អ្នកឡើងវិញ ដើម្បីធ្វើផែនការឱ្យបានត្រឹមត្រូវ តើអ្នកត្រូវកែប្រែទៅលើចំណុចអ្វីខ្លះ?

---

## ការបង្កើតតារាងគ្រោងថវិកាប្រចាំខែ

១. ដោយផ្អែកលើតួលេខសៀវភៅកត់ត្រាប្រចាំថ្ងៃរបស់អ្នក និង ថវិកាពង្រាងប្រចាំសប្តាហ៍ដែលអ្នកបានធ្វើ ចូរបង្កើតតារាងគ្រោងថវិកាសម្រាប់ប្រាក់ចំណូលប្រចាំខែ និង ការចំណាយ ។

២. ផ្អែកលើបទពិសោធន៍គ្រោងថវិកាប្រចាំ សប្តាហ៍របស់អ្នកអាចធ្វើការកែប្រែប្រភេទចំណាយរបស់អ្នក ឱ្យបានសមស្រប ។

៣. ផ្អែកលើចំនួនប្រាក់ចំណាយដែលបានប៉ាន់ស្មានទុក សម្រាប់ខែក្រោយអ្នកអាចបញ្ចូលលេខសម្រាប់ជួរ " **ថវិកា** " របស់អ្នក ។

៤. រក្សាព័ត៌មានក្នុងសៀវភៅកត់ត្រាប្រចាំថ្ងៃសម្រាប់សកម្មភាព ៤ នៅសប្តាហ៍ក្រោយទៀត ។

៥. យើងនឹងត្រឡប់មកពិនិត្យមើលឡើងវិញ និង បំពេញព័ត៌មាននៅក្នុងប្រអប់ " **ចំនួនជាក់ស្តែង** " និង ប្រអប់ " **ភាពខុសគ្នា** " ។

# មេរៀនទី៨ : ការរៀបចំបញ្ជីគណនេយ្យគោលសម្រាប់ការធ្វើជំនួញ

☼ **លទ្ធផលសិក្សារំពឹងទុក**

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច :

- ពន្យល់ពីសារៈសំខាន់នៃការរៀបចំបញ្ជីគណនេយ្យនៅក្នុងកិច្ចការជំនួញ
- លើកឧទាហរណ៍ពីការអនុវត្តល្អ និង មិនល្អក្នុងការចំណាយក្នុងកិច្ចការជំនួញ ព្រមទាំងបញ្ជាក់ពីមូលហេតុ
- លើកឧទាហរណ៍បានយ៉ាងតិច ៥ ពីប្រាក់ចូល និងប្រាក់ចេញនៅក្នុងការងារជំនួញ។

## ការចាប់ផ្តើម

នៅប្រទេសកម្ពុជាមាន ក្រុមគ្រួសារ និងសហគមន៍ជាច្រើនបានចូលរួមក្នុងសកម្មភាពបង្កើតប្រាក់ចំណូល ដើម្បីរកចំណូលចូលផ្ទះ។ ការយល់ដឹងពីគោលការណ៍គ្រឹះនៃការគ្រប់គ្រង ប្រាក់មានសារៈសំខាន់ណាស់ ដើម្បីរក្សាប្រាក់ចំណូលជាជាងបាត់បង់ប្រាក់ ក្នុងគោលបំណងធ្វើឱ្យមាននិរន្តរភាពនៃការរកចំណូលចូលផ្ទះឱ្យបានយូរអង្វែង។

## ការធ្វើជំនួញនៅក្នុងសហគមន៍របស់អ្នក

☝ តើជំនួញជាអ្វី?/ដូចម្តេចហៅថាជំនួញ?

______________________________

______________________________

______________________________

☝ នៅក្នុងសហគមន៍របស់អ្នកមានប្រភេទជំនួញអ្វីខ្លះ?

______________________________

______________________________

______________________________

______________________________

______________________________

☞ ក្នុងការធ្វើជំនួញ តើគេត្រូវធ្វើដូចម្តេចទើបចាំបានថាមានប្រាក់ប៉ុន្មានចូល និងមានប្រាក់ប៉ុន្មានត្រូវចំណាយ?

☞ តើ "**បញ្ជីគណនេយ្យ**" មានន័យដូចម្តេច?

☞ តើការរៀបចំបញ្ជីគណនេយ្យមានសារៈសំខាន់ដូចម្តេចខ្លះ?

ការសម្តែងតួស្តីពីការតាមដានការចំណាយ

**ការសម្តែងតួទី១ :** ស្ត្រីម្នាក់មានមុខជំនួញមួយ (ជ្រើសរើសមុខជំនួញមួយដែលក្រុមធ្លាប់ស្គាល់) ។ គាត់មិនធ្លាប់កត់ត្រាពីចំនួនប្រាក់ចំណូលនិងចំណាយទេ ។ ថ្ងៃមួយ កូនប្រុសរបស់គាត់បានត្រឡប់ពីសាលារៀនវិញ ដោយមានសំបុត្រមួយច្បាប់ដែលនាយកសាលាផ្ញើមកផង ។ សាលាបានស្នើសុំថវិកាខ្លះ ដើម្បីប្រើការក្នុងដំណើរទស្សនកិច្ចសិក្សារបស់សិស្សដែលសាលារៀបចំធ្វើសម្រាប់លើកកម្ពស់កម្មវិធីសិក្សាបំណិនជីវិត ។ ក្នុងរយៈពេលមួយខែកន្លងមកហើយដែលសាលាបានផ្សព្វផ្សាយផែនការទស្សនកិច្ចសិក្សានេះ ហើយសមាគមមាតាបិតាសិស្សក៏បានឯកភាពលើផែនការនេះដែរ ។ ស្ត្រីជាម្តាយមានការព្រួយបារម្ភយ៉ាងខ្លាំងអំពីរឿងនេះ ។ គាត់គិតថាខ្លួនគាត់គ្មានប្រាក់ទេ ។ គាត់បានព្យាយាមនឹកគិតពីចំនួនប្រាក់ដែលគាត់រកបានកាលពីសប្តាហ៍មុន និងចំនួនប្រាក់ដែលគាត់បានចំណាយ ។

(១). តើស្ត្រីនោះមានបញ្ហាអ្វី? (២).តើគាត់គួរធ្វើដូចម្តេចដើម្បីជៀសវាងបញ្ហានោះ?

**ការសម្តែងតួទី២ :** ជាងឈើម្នាក់បានលក់ទូមួយឱ្យទៅភ្ញៀវម្នាក់តម្លៃ ១៥០ ០០០ រៀល ។ ពេលមកយកទូភ្ញៀវបានប្រាប់ជាងឈើថា ពេលនេះគាត់មិនបានយកប្រាក់មកជាមួយទេ ប៉ុន្តែគាត់នឹងប្រគល់ប្រាក់ឱ្យនៅចុងខែនេះ ។ នៅចុងខែជាងឈើក៏បានទៅទារប្រាក់ពីភ្ញៀវនោះ ។ ភ្ញៀវនោះបាននិយាយថា គាត់ជំពាក់ប្រាក់ថ្លៃទូតែ ១២០ ០០០ រៀលប៉ុណ្ណោះ គាត់មិនឱ្យប្រាក់ទៅជាងឈើលើសពីចំនួន ១២០ ០០០ រៀលនោះឡើយ ។ អាស្រ័យហេតុនេះការជជែកដ៏តឹងតែងក៏កើតមានឡើង ។ ប៉ុន្តែជាងឈើគ្មានភស្តុតាងដែលបញ្ជាក់ថាគាត់បានលក់ទូជើរក្នុងតម្លៃ ១៥០ ០០០ រៀល នោះទេ ហើយជាងឈើក៏បានសម្រេចចិត្តទទួលយកប្រាក់ថ្លៃលក់ទូតម្លៃ ១២០ ០០០ រៀល ។

(១) ហេតុអ្វីបានជាភ្ញៀវអាចបន្លំប្រាក់ថ្លៃលក់ទូរបស់ជាងឈើបាន?(២) តើជាងឈើគួរធ្វើដូចម្តេចដើម្បីជៀសវាងបញ្ហានេះ?

**ការសម្តែងតួទី ៣ :** ស្ត្រីមួយក្រុមរស់នៅក្នុងសហគមន៍មានឡធ្វើនំប៉័ងមួយ ។
ពួកគេបានបែងចែកការងារដូចខាងក្រោម :

- ស្ត្រីម្នាក់ជាអ្នកទទួលខុសត្រូវទិញអុស និង គ្រឿងផ្សំសម្រាប់ធ្វើនំប៉័ង
- ស្ត្រីម្នាក់ត្រូវទទួលខុសត្រូវក្នុងការលក់នំប៉័ង
- ស្ត្រីមួយក្រុមជួយច្របាច់ម្សៅ និង ដុតនំប៉័ង
- ស្ត្រីម្នាក់ជាហិរញ្ញិកដែលទទួលខុសត្រូវក្នុងការទុកដាក់ប្រាក់ឱ្យមានសុវត្ថិភាព ។

ស្ត្រីដែលជាអ្នកលក់មិនបានកត់ត្រាចំនួនប្រាក់ចំណូលទេ ។ ពេលនាងលក់បាន នាងបានប្រគល់ប្រាក់ទៅឱ្យហិរញ្ញិកដើម្បីរៀបចំទុកដាក់នៅក្នុងហិបប្រាក់ ។ ហិរញ្ញិកជាអ្នកបើកប្រាក់ឱ្យស្ត្រីដែលត្រូវយកទៅ ទិញអុស និងគ្រឿងផ្សំធ្វើនំប៉័ង ។ ហិរញ្ញិកជាមនុស្សម្នាក់ដែលគួរឱ្យទុកចិត្តណាស់ ប៉ុន្តែនាងមិនចេះអក្សរទេ ។ នៅចុងខែ សមាជិកក្រុមចង់ដឹងពីចំនួនប្រាក់ចំណូលដែលបានមកពីការលក់នំប៉័ង ។ នៅពេលបើកហិបប្រាក់ ពួកគេឃើញមានប្រាក់តិចជាងការរំពឹងទុក ។ គ្មាននរណាម្នាក់ដឹងថាមានរឿងអ្វីកើតឡើងចំពោះប្រាក់ទាំងនោះឡើយ ។ បន្ទាប់ពីពិភាក្សាគ្នាមកពួកគេបានចោទប្រកាន់ស្ត្រីអ្នកលក់នំប៉័ងថាជាអ្នកបានលួចប្រាក់នោះ ។

(១) ហេតុអ្វីបានជាសមាជិកក្រុមស្ត្រីនៅឡធ្វើនំប៉័ងខឹង? (២) តើពួកគេគួរធ្វើដូចម្តេច ដើម្បីជៀសវាងបញ្ហាបែបនេះ?

_______________________________________________
_______________________________________________
_______________________________________________
_______________________________________________
_______________________________________________

## ការបង្កើតប្រាក់ចំណូល និង ប្រាក់ចំណាយនៅក្នុងការធ្វើជំនួញ

ចូរលើកឧទាហរណ៍ពីវិធីដែលធ្វើឱ្យមានប្រាក់ចំណូល និង ប្រាក់ចំណាយ នៅក្នុងការធ្វើជំនួញ ។

| - (ចំណាយ) | +(ចំណូល) |
|---|---|
| | |
| (➢ចម្លើយរំពឹងទុក : ផលិតផលដែលខូច ឬ បាត់បង់ ការលក់ជឿ មធ្យោបាយបាយដឹកជញ្ជូន ឬ សេវាកម្មអ្នកលើកដាក់ ។ល ។) | (➢ចម្លើយរំពឹងទុក : ការលក់ផលិតផល ការសងប្រាក់ថ្លៃទំនិញដែលគេទិញជឿ ការសងថ្លៃការប្រាក់ ។ល ។) |

# មេរៀនទី៩ : តារាងលំហូរសាច់ប្រាក់សម្រាប់ការធ្វើជំនួញ

☼ **លទ្ធផលសិក្សារំពឹងទុក**

នៅពេលរៀនមេរៀននេះចប់ សិស្សនឹងអាច :

- បំពេញតារាងលំហូរសាច់ប្រាក់
- ពិនិត្យមើលកំហុសដែលមាននៅក្នុងតារាងលំហូរសាច់ប្រាក់ ។

## តារាងលំហូរសាច់ប្រាក់

តារាងលំហូរសាច់ប្រាក់ដែលយើងយកមកប្រើមានលក្ខណៈដូចខាងក្រោម :

| កាលបរិច្ឆេទ | ការទិញលក់ទំនិញ | មុខទំនិញ/សេវាកម្ម | | | ប្រាក់ចំណាយ (–) | ប្រាក់ចំណូល (+) | សមតុល្យ |
|---|---|---|---|---|---|---|---|
| | | មុខទំនិញ | បរិមាណ | តម្លៃលក់រាយ | | | |
| | | | | | | សមតុល្យដំបូង | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

សរសេរឧទាហរណ៍ ឬ ព័ត៌មានដែលត្រូវដាក់នៅក្រោមចំណងជើងនីមួយៗក្នុងតារាង ។

| | |
|---|---|
| ១. កាលបរិច្ឆេទ | |
| ២. ការទិញលក់ទំនិញ | |
| ៣. មុខទំនិញ/សេវាកម្ម | |
| ៣.១. មុខទំនិញ | |
| ៣.២. បរិមាណ | |
| ៣.៣ តម្លៃលក់រាយ | |
| ៤. ប្រាក់ចំណូល/ប្រាក់ចំណាយ | |
| ៥. សមតុល្យ | |

**ករណីសិក្សារបស់ "ស្រស់"**

ស្រស់មានបំណងធ្វើជំនួញផ្ទាល់ខ្លួននៅផ្សារ ។ នាងមានប្រាក់តែមួយចំនួនតូចប៉ុណ្ណោះ ។ ដូច្នេះនាងចាប់ផ្តើមធ្វើជំនួញតូចមួយ ។ នាងសង្ឃឹមថាមុខជំនួញរបស់នាងនឹងរីកចម្រើន ។

- ស្រស់ចាប់ផ្តើមមុខជំនួញជាមួយនឹងទឹកប្រាក់ចំនួន ៥០ ០០០ រៀល ។
- នៅព្រឹកថ្ងៃទី ២ ខែធ្នូ នាងបានទៅផ្សារ និង បានទិញមុខទំនិញដូចខាងក្រោម :
    - ប៉េងប៉ោះ៦ គីឡូក្រាម ក្នុង១គីឡូក្រាមថ្លៃ ៣ ០០០ រៀល (៦×៣ ០០០=១៨ ០០០)
    - ការ៉ុត៤ គីឡូក្រាម ក្នុង១គីឡូក្រាមថ្លៃ ៣ ២០០ រៀល (៤×៣ ២០០=១២ ៨០០)
    - ត្រកួន៨បាច់ ក្នុង១បាច់ថ្លៃ ១ ០០០ រៀល (៨×១ ០០០=៨ ០០០)
    - ខ្ទឹមបារាំង៣គីឡូក្រាម ក្នុង១គីឡូក្រាមថ្លៃ ៣ ១០០ រៀល (៣×៣ ១០០=៩ ៣០០)
    - ម្ទេសហឺរ ៥០ផ្លែ ថ្លៃ ៧៥០ រៀល
- នៅថ្ងៃនោះ នាងបានលក់មុខទំនិញខាងលើក្នុងតម្លៃដូចខាងក្រោម :
    - ប៉េងប៉ោះ ២,៥ គីឡូក្រាម ក្នុង១គីឡូក្រាមថ្លៃ ៣ ៥០០ រៀល
    - ការ៉ុត ៣ គីឡូក្រាម ក្នុង១គីឡូក្រាមថ្លៃ ៣ ៥០០ រៀល
    - ត្រកួន ៥បាច់ ក្នុង១បាច់ថ្លៃ ១ ២៥០ រៀល
    - ខ្ទឹមបារាំង៣គីឡូក្រាម ក្នុង១គីឡូក្រាមថ្លៃ ៣ ៥០០ រៀល
    - ម្ទេសហឺរ៣០ផ្លែ ក្នុង៥ផ្លែ ថ្លៃ ១០០ រៀល
- នៅរសៀលថ្ងៃទី ២ ខែធ្នូ ស្រស់បានចំណាយប្រាក់ ៥ ០០០ រៀល ទិញម្ហូបសម្រាប់គ្រួសាររបស់នាង ។
- នៅថ្ងៃទី ៣ ខែធ្នូ ស្រស់លក់ទំនិញដែលនៅសល់បន្តទៀត ។ ដោយសារទំនិញដែលនៅសល់មិនសូវស្រស់ល្អ នាងលក់ក្នុងតម្លៃថោកជាងមុនបន្តិច ។
    - ប៉េងប៉ោះ ២,៥ គីឡូក្រាម ក្នុង១គីឡូក្រាមថ្លៃ ៣ ៤០០ រៀល
    - ការ៉ុត១គីឡូក្រាម ក្នុង១គីឡូក្រាមថ្លៃ ៣ ៥០០ រៀល
    - ត្រកួន ៣ បាច់ ក្នុង១បាច់ថ្លៃ ១ ១០០ រៀល
    - ម្ទេសហឺរ ១០ ផ្លែ ក្នុង៥ផ្លែ ថ្លៃ ៧៥ រៀល

ចូរធ្វើតារាងលំហូរសាច់ប្រាក់សម្រាប់ករណីសិក្សារបស់ "ស្រស់"

| កាលបរិច្ឆេទ | ការទិញលក់ទំនិញ | មុខទំនិញ/សេវាកម្ម | | | ប្រាក់ចំណាយ (-) | ប្រាក់ចំណូល (+) | សមតុល្យ |
|---|---|---|---|---|---|---|---|
| | | មុខទំនិញ | បរិមាណ | តម្លៃលក់រាយ | | | |
| | | | | | | សមតុល្យដំបូង | ៥០ ០០០ |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

**សំណួរពិភាក្សា ៖**

១. តើស្រស់បញ្ចប់ការលក់ដូរដោយទទួលបានប្រាក់ចំណេញ ឬ ខាត?

២. តើប្រាក់ចំណេញនៅពេលធ្វើសមតុល្យចុងក្រោយមានប៉ុន្មាន?

៣. តើមុខទំនិញអ្វីដែលស្រស់បានដាក់បញ្ចូលទៅក្នុងតារាងលំហូរសាច់ប្រាក់ដែលមិនមែនជាប្រាក់ចំណាយធ្វើជំនួញ?

៤. តើប្រាក់ចំណេញពិតប្រាកដដែលលក់ក្នុងថ្ងៃដំបូងមានចំនួនប៉ុន្មាន?

៥. តើមានមុខទំនិញអ្វីខ្លះដែលស្រស់ត្រូវលក់បន្ត?

៦. តើស្រស់ទទួលបានប្រាក់ចំណេញសម្រាប់ទ្រទ្រង់មុខជំនួញរបស់នាងបានដែរឬទេ?

៧. តើស្រស់ត្រូវធ្វើដូចម្តេច ដើម្បីបង្កើនប្រាក់ចំណេញបន្ថែមទៀត?

| ករណីសិក្សារបស់ សុភ័ក្រ |
|---|

**សុភ័ក្រ** មានបំណងប្រកបមុខរបរលក់ផ្លែឈើ ។ នាងបានខ្ចីប្រាក់ពីពូនាងចំនួន ៣០០ ០០០៛ ។ ឪពុកនាងបានឱ្យនាងខ្ចីរទេះដាក់ផ្លែឈើលក់ ។

- **សុភ័ក្រ** ចាប់ផ្តើមប្រកបមុខរបរលក់ផ្លែឈើជាមួយនឹងប្រាក់ ៣០០ ០០០ រៀល ។
- នៅព្រឹកថ្ងៃទី ១ ខែធ្នូ នាងបានទៅមើលតម្លៃផ្លែឈើនៅផ្សារ ។ នៅពេលរសៀលនាងបានសម្រេចចិត្តទិញប្រភេទផ្លែឈើមួយចំនួន ដូចខាងក្រោម ៖

- ផ្លែស្វាយ៥ គីឡូក្រាម ក្នុង១គីឡូក្រាមថ្លៃ ៥ ០០០ រៀល (៥×៥ ០០០=២៥ ០០០)
- ផ្លែសាវម៉ាវ៥ គីឡូក្រាម ក្នុង១គីឡូក្រាមថ្លៃ ៥ ៥០០ រៀល (៥×៥ ៥០០=២៧ ៥០០)
- ក្រូចថ្លុងមតូច១៥គីឡូក្រាម ក្នុង១គីឡូក្រាមថ្លៃ ៥ ៥០០ រៀល (១៥×៥ ៥០០=៨២ ៥០០)
- ផ្លែព័រអាស៊ី៥គីឡូ ក្នុង១គីឡូ ថ្លៃ ៥ ៦០០ រៀល (៥×៥ ៦០០=២៨ ០០០)
- ផ្លែប៉ោមល្អ៦ គីឡូក្រាម ក្នុង១គីឡូក្រាមថ្លៃ ១០ ០០០ រៀល (៦×១០ ០០០=៦០ ០០០)

- នៅថ្ងៃទី១ ខែធ្នូ នាងបានទិញកញ្ច្រែង ចំនួន ៥ ដើម្បីដាក់ផ្លែឈើ ។ កញ្ច្រែង១ថ្លៃ ១៥ ០០០ រៀល ។
- នៅល្ងាចថ្ងៃទី ១ ខែធ្នូ **សុភ័ក្រ** និង ប្អូនស្រីរបស់នាងបានរុញរទេះផ្លែឈើទៅលក់នៅសួនឧទ្យាន ដែលមានមនុស្សជាច្រើនមកដើរលេងកំសាន្ត ។ ប្រភេទផ្លែឈើដែលនាងលក់មានដូចខាងក្រោម :
    - ផ្លែស្វាយ ២ គីឡូក្រាម ក្នុង១គីឡូក្រាមថ្លៃ ៥ ៥០០ រៀល
    - ផ្លែសាវម៉ាវ៤គីឡូក្រាម ក្នុង១គីឡូក្រាមថ្លៃ ៦ ៣០០ រៀល
    - ក្រូចថ្លុងមតូច១ ១១គីឡូក្រាម ក្នុង១គីឡូក្រាមថ្លៃ ៦ ២០០ រៀល
    - ផ្លែព័រអាស៊ី៣គីឡូ ក្នុង១គីឡូក្រាម ថ្លៃ ៦ ៣០០ រៀល
    - ផ្លែប៉ោមល្អ៤ គីឡូក្រាម ក្នុង១គីឡូក្រាមថ្លៃ ១៥ ០០០ រៀល
- នៅល្ងាចថ្ងៃទី ១ ខែធ្នូ **សុភ័ក្រ**បានឱ្យប្រាក់ទៅប្អូនស្រីរបស់នាងចំនួន ៤ ០០០ រៀល សម្រាប់ការជួយរុញរទេះ ។
- នៅថ្ងៃទី ២ ខែធ្នូ **សុភ័ក្រ**បានបន្តលក់ផ្លែឈើដែលនៅសល់តែម្នាក់ឯងនៅតាមដងផ្លូវ ។ ប៉ុន្តែដោយសារផ្លែឈើដែលនៅសល់មិនសូវស្រស់ នាងលក់តម្លៃថោកជាងមុនបន្តិច ។
    - ផ្លែស្វាយ ថ្លៃ ៥ ២០០ រៀល ក្នុង១ គីឡូក្រាម
    - ផ្លែសាវម៉ាវ ថ្លៃ ៥ ៤០០ រៀល ក្នុង១ គីឡូក្រាម
    - ក្រូចថ្លុងមតូច១ ថ្លៃ ៥ ៣០០ រៀល ក្នុង១ គីឡូក្រាម
    - ផ្លែព័រអាស៊ី ថ្លៃ ៦ ០០០ រៀល ក្នុង១ គីឡូក្រាម
    - ផ្លែប៉ោមល្អ លក់ក្នុងថ្លៃដដែល ។

ចូរធ្វើតារាងលំហូរសាច់ប្រាក់សម្រាប់ករណីសិក្សារបស់ "សុភ័ក្រ "

| កាលបរិច្ឆេទ | ការទិញលក់ទំនិញ | មុខទំនិញ/សេវាកម្ម | | | ប្រាក់ចំណាយ (–) | ប្រាក់ចំណូល (+) | សមតុល្យ |
|---|---|---|---|---|---|---|---|
| | | មុខទំនិញ | បរិមាណ | តម្លៃលក់រាយ | | | |
| | | | | | | សមតុល្យដំបូង | ៣00 000 |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |
| | | | | | | | |

**សំណួរពិភាក្សា ៖**

១. តើការធ្វើជំនួញរបស់សុភ័ក្រទទួលបានប្រាក់ចំណេញឬខាត?

២. ហេតុអ្វីបានជានាងលក់ផ្លែឈើខាតនៅថ្ងៃនេះ?

៣. តើសុភ័ក្រនឹងបានប្រាក់ចំណូលប៉ុន្មានពីការលក់ បើមិនគិតបញ្ចូលថ្លៃទិញកញ្ច្រែង?

៤. ប្រសិនបើសុភ័ក្រមានប្រាក់ចំណូល និង ចំណាយដដែល តើនាងត្រូវលក់ដូរប៉ុន្មានដងទើបរួចថ្លៃទិញកញ្ច្រែង?

៥. តើអ្នកមានយោបល់អ្វីសម្រាប់ជួយធ្វើឱ្យមុខជំនួញរបស់សុភ័ក្ររីកចម្រើន?

៦. តើអ្នកគិតថាមុខជំនួញរបស់ស្រស់ ឬ សុភ័ក្រ អាចនឹងរីកចម្រើននៅពេលអនាគតដែលឬទេ? ហេតុអ្វី?

## មេរៀនទី១០ : ការស្វែងយល់ពីការរៀបចំបញ្ជីគណនេយ្យ

**☼ លទ្ធផលសិក្សារំពឹងទុក**

ពេលរៀនមេរៀននេះចប់ សិស្សនឹងអាច :

- ធ្វើតារាងបង្ហាញពីតំរិយាបថសមស្របសម្រាប់ប្រើក្នុងការធ្វើសម្ភាស
- ធ្វើសម្ភាសជាមួយអ្នកជំនួញនៅក្នុងសហគមន៍
- កំណត់ព័ត៌មានសំខាន់ៗក្នុងការធ្វើសម្ភាសដែលអាចផ្តល់ជាមធ្យោបាយសម្រាប់ឱ្យគេយកទៅអនុវត្តក្នុងការរៀបចំបញ្ជីគណនេយ្យបានល្អប្រសើរ ។

### សំណួរសម្ភាសសំខាន់ៗស្តីពីការរៀបចំបញ្ជីគណនេយ្យ

តាមរយៈការសម្ភាសអ្នកធ្វើជំនួញនៅក្នុងសហគមន៍ យើងអាចស្វែងយល់បានច្រើនអំពីរបៀបរៀបចំបញ្ជីគណនេយ្យស្តីពីប្រាក់ចំណូល និងប្រាក់ចំណាយ ព្រមទាំងបានរៀនពីបទពិសោធន៍របស់ពួកគាត់ទៀតផង ។

នេះជាសំណួរសំខាន់ៗមួយចំនួនដែលយើងអាចប្រើសម្រាប់ធ្វើសម្ភាសន៍ :

១. តើប្រព័ន្ធនៃការរៀបចំបញ្ជីគណនេយ្យដែលបង/ពូ/មីង/អ៊ំប្រើមានអ្វីខ្លះ?

២. តើបញ្ហាប្រឈមអ្វីខ្លះដែលបង/ពូ/មីង/អ៊ំ ជួបប្រទះក្នុងការរៀបចំបញ្ជីគណនេយ្យ?

៣. តើប្រភេទប្រាក់ចំណូល និង ចំណាយ( ការលក់ទំនិញ ការខ្ចីប្រាក់ ការទិញជឿ ការចំណាយលើកិច្ចការសេវាកម្ម) អ្វីខ្លះដែលអ្នកត្រូវតាមដាន?

៤. តើបង/ពូ/មីង/អ៊ំ អាចប្រាប់ពីបទពិសោធន៍មិនល្អដែល បង/ពូ/មីង/អ៊ំ ធ្លាប់ជួបប្រទះពេលរៀបចំបញ្ជីគណនេយ្យបានដែរឬទេ?

៥. តើបង/ពូ/មីង/អ៊ំ អាចប្រាប់ពីបទពិសោធន៍ល្អៗដែលបង/ពូ/មីង/អ៊ំធ្លាប់ជួបប្រទះពេលរៀបចំបញ្ជីគណនេយ្យបានដែរឬទេ?

អ្នកអាចប្រើសំណួរផ្ទាល់របស់អ្នកបានដើម្បីសួរទៅអ្នកធ្វើជំនួញទាំងនោះ ។ ចូរសរសេរសំណួររបស់អ្នកនៅខាងក្រោមនេះ ឬ នៅលើក្រដាសផ្សេងទៀត ។

# សៀវភៅសិស្ស

តើអ្នកជំនួញណាខ្លះនៅក្នុងសហគមន៍ដែលសិស្សយើងត្រូវធ្វើសម្ភាស?

______________________________

______________________________

______________________________

## ការប្រកាន់កិរិយាបថសមរម្យពេលធ្វើសម្ភាស

នៅពេលធ្វើសម្ភាស យើងត្រូវប្រកាន់កិរិយាបថសមរម្យមួយចំនួន :

☺ សុភាពរាបសា និង ចេះគួរសម

☺ ត្រូវធ្វើការណែនាំខ្លួន

☺ ប្រាប់ពីគោលបំណងនៃការធ្វើសម្ភាស

☺ សុំការអនុញ្ញាតពីអ្នកធ្វើជំនួញ ២ ឬ ៣ នាទី ដើម្បីធ្វើសម្ភាស

☺ ត្រូវថ្លែងអំណរគុណពេលសម្ភាសចប់ ។

ចូរផ្តល់ពីកិរិយាបថល្អផ្សេងទៀត :

☺ ______________________________

☺ ______________________________

☺ ______________________________

# មេរៀនទី ១១ និង ១២ : ការកំណត់តម្លៃទំនិញ និងការស្វែងយល់ពីបញ្ហាកំណត់តម្លៃ

**☼ លទ្ធផលសិក្សារំពឹងទុក**

ពេលរៀនមេរៀននេះចប់សិស្សនឹងអាច :

**មេរៀនទី ១១ :**

- កំណត់និយមន័យប្រាក់ចំណូល ប្រាក់ចំណេញ និង ប្រាក់ខាត នៅក្នុងការរៀបចំបញ្ជីគណនេយ្យ
- បំពេញតារាងលំហូរសាច់ប្រាក់ជាមូលដ្ឋានសម្រាប់ការធ្វើជំនួញ
- ប៉ាន់ស្មានតម្លៃលក់តាមរយៈតារាងលំហូរសាច់ប្រាក់ ។

**មេរៀនទី ១២ :**

- សម្ភាសជាមួយអ្នកលក់ដូរនៅតាមផ្សារក្នុងមូលដ្ឋាន
- បង្ហាញពីលទ្ធផលនៃការសម្ភាសដល់សិស្សទាំងអស់នៅក្នុងថ្នាក់
- ប្រើបទពិសោធន៍នៃការសម្ភាសតាមផ្សារ ដើម្បីគណនាពីតម្លៃ
- ពន្យល់ពីគុណសម្បត្តិ និង គុណវិបត្តិមុខជំនួញតាមផ្សារ
- បង្ហាញពីវិធីដែលអ្នកលក់ប្រើដើម្បីទាក់ទាញ ឬ រក្សាភ្ញៀវ ។

## និយមន័យនៃប្រាក់ចំណូល ប្រាក់ចំណេញ និង ប្រាក់ខាត

ការសិក្សាមេរៀនទាំងនេះគឺជាការស្វែងយល់ពីភាពខុសគ្នារវាងប្រាក់ចំណូល និងប្រាក់ចំណេញ និងជាការបង្ហាញឱ្យយើងដឹងពីការធ្វើជំនួញចំណេញឬខាត ។ ប្រសិនបើមុខជំនួញរបស់យើងបានចំណេញ យើងមានឱកាសក្នុងការពង្រីកមុខជំនួញ ហើយយើងក៏មានប្រាក់សម្រាប់ចំណាយផងដែរ ។ ប្រសិនបើយើងខាត យើងមិនអាចទ្រទ្រង់ជីវភាព មិនអាចសងបំណុលគេ ហើយប្រាក់ផ្ទាល់ខ្លួនក៏ត្រូវកាត់បន្ថយ យើងមិនអាចមានលទ្ធភាពបន្តមុខជំនួញបានទៀតទេ ។

១. ចូរសរសេរនិយមន័យនៃ ប្រាក់ចំណូល ប្រាក់ចំណេញ និង ប្រាក់ខាត :

**ប្រាក់ចំណូល**

________________________________________

________________________________________

**ប្រាក់ចំណេញ**

**ប្រាក់ខាត**

២. តើប្រាក់ចំណូល និងប្រាក់ចំណេញខុសគ្នាដូចម្ដេច?

## ការកំណត់តម្លៃសម្រាប់មុខទំនិញ ឬ សេវាកម្ម

១. តើនៅក្នុងសហគមន៍របស់អ្នកមានប្រភេទមុខជំនួញអ្វីខ្លះ?

២. ឧទាហរណ៍ពីមុខជំនួញនៅក្នុងមូលដ្ឋានដែលគ្រូបានលើកឡើង គឺបង្ហាញឱ្យឃើញពីវិធីនៃការធ្វើជំនួញដែលទទួលបានប្រាក់ចំណូល និងការចំណាយប្រាក់សម្រាប់ការធ្វើជំនួញ។

| **(+) ប្រាក់ចំណាយ** | **(-) ប្រាក់ចំណូល** |
|---|---|
| | |

ដើម្បីកំណត់តម្លៃមុខទំនិញ ឬការផ្តល់សេវាកម្មសម្រាប់ការធ្វើជំនួញនោះ គេគួរតែដឹងច្បាស់ពីប្រាក់ចំណូល និងចំណាយដែលគេអាចរំពឹងថានឹងកើតមានក្នុងការធ្វើជំនួញ ដូចនេះគេអាចធ្វើការកំណត់តម្លៃលក់ទំនិញ និងការផ្តល់សេវាកម្មបាន។

១. តើទំនិញ ឬការផ្តល់សេវាកម្មដែលអ្នកបានកំណត់គឺអ្វី?

២. តើក្រុមរបស់អ្នកបានកំណត់តម្លៃសម្រាប់មុខទំនិញ ឬ ការផ្តល់សេវាកម្មប៉ុន្មាន?

# សៀវភៅសិស្ស

## ការសម្ភាសពីតម្លៃទំនិញជាមួយអ្នកជំនួញក្នុងមូលដ្ឋាន

ដើម្បីស្វែងយល់បន្ថែមទៀតពីភាពត្រឹមត្រូវនៃការកំណត់តម្លៃទំនិញ យើងត្រូវសម្ភាសជាមួយមនុស្សមានបទពិសោធន៍ក្នុងការលក់ផលិតផល ឬផ្តល់សេវាកម្មផ្នែកនេះ ។

សំណួរសំខាន់ៗមួយចំនួនដែលយើងប្រើសម្រាប់ធ្វើសម្ភាស

១. តើទំនិញដែលបង/ពូ/មីង/អ៊ំលក់គេឱ្យតម្លៃប៉ុន្មាន?

២. ជាធម្មតាតើបង/ពូ/មីង/អ៊ំលក់ថ្លៃប៉ុន្មាន?

៣. តើបង/ពូ/មីង/អ៊ំបានកំណត់តម្លៃលក់ដោយរបៀបណា?

៤. ក្នុងមួយឆ្នាំៗ តើតម្លៃលក់មានការប្រែប្រួលដែរឬទេ? ហេតុអ្វី?

៥. ក្នុងការកំណត់តម្លៃ តើជួបប្រទះការលំបាកអ្វីខ្លះ?

៦. ជានិច្ចកាល តើបង/ពូ/មីង/អ៊ំទទួលបានប្រាក់ចំណេញក្នុងការលក់មែនឬទេ? បើមិនចំណេញ តើមកពីមូលហេតុអ្វីខ្លះ?

៧. តើបង/ពូ/មីង/អ៊ំធ្វើដូចម្តេច ដើម្បីទាក់ទាញ ឬរក្សាភ្ញៀវរបស់បង/ពូ/មីង/អ៊ំ?

## បង្ហាញលទ្ធផលនៃការសម្ភាសស្តីពីការកំណត់តម្លៃ

តើព័ត៌មានសំខាន់អ្វីខ្លះដែលអ្នកបានពីការធ្វើសម្ភាសហើយអ្នកត្រូវបង្ហាញដល់គ្រូរបស់អ្នក និង សិស្សក្នុងថ្នាក់?

១. ចូររៀបរាប់ដោយសង្ខេបពីមនុស្សដែលអ្នកបានសម្ភាស និង មុខជំនួញរបស់ពួកគាត់ ។

___

___

___

២. ចូររៀបរាប់ដោយសង្ខេបពីមុខទំនិញ ឬសេវាកម្មដែលអ្នកធ្វើជំនួញក្នុងមូលដ្ឋានម្នាក់បានធ្វើ ។

___

___

___

៣. ចូរសរសេរចម្លើយចំពោះសំណួរដែលបានសួរ ។

| អ្នកគួរសរសេរចម្លើយទាំងនេះនៅលើក្រដាសផ្សេងពីគ្នា |
| --- |

៤. ចូរបញ្ជាក់ពីចំណុចដែលថា ការធ្វើសម្ភាសនេះបានជួយឱ្យអ្នកយល់ពីភាពត្រឹមត្រូវនៃតម្លៃទំនិញដែលអ្នកបានកំណត់ ។

៥. តើមានភាពខុសគ្នាអ្វីខ្លះរវាងប្រាក់ចំណូល និងចំណាយដែលអ្នកធ្វើជំនួញបានប្រាប់ ជាមួយនឹងតារាងប្រាក់ចំណូល និងចំណាយក្នុងក្រុមរបស់អ្នក?

៦. តើមានបច្ចេកទេសអ្វីខ្លះដែលពួកគាត់ប្រើដើម្បីទាក់ទាញ ឬរក្សាភ្ញៀវរបស់គាត់?

**ការវាយតម្លៃឡើងវិញលើតម្លៃទំនិញរបស់យើង**

១. តើតម្លៃលក់របស់អ្នកស្ថិតនៅក្រោម ឬនៅលើអត្រាតម្លៃលក់នៅទីផ្សារ?

២. ផ្អែកលើការសម្ភាស តើអ្នកគួរកែប្រែព័ត៌មាននៅក្នុងតារាងប្រាក់ចំណូល និងប្រាក់ចំណាយរបស់អ្នកដែរឬទេ?

៣. ផ្អែកលើការសម្ភាសរបស់អ្នក តើក្រុមរបស់អ្នកគួរកំណត់តម្លៃលក់ទំនិញ ឬសេវាកម្មរបស់អ្នកប៉ុន្មាន ដើម្បីធ្វើឱ្យមានប្រាក់ចំណេញ និងមានលក្ខណៈប្រកួតប្រជែងតម្លៃ?

៤. តើមានគុណសម្បត្តិ និង គុណវិបត្តិអ្វីខ្លះចំពោះការប្រកបមុខជំនួញនៅទីផ្សាររបស់អ្នក?

៥. តើមានវិធីសាស្ត្រអ្វីខ្លះដែលអ្នកចង់យកទៅអនុវត្តតាមសម្រាប់ទាក់ទាញ និងរក្សាភ្ញៀវ?

**ការពិនិត្យឡើងវិញលើតារាងគ្រោងថវិកាប្រចាំខែផ្ទាល់ខ្លួន**

១. ការគ្រោងថវិកាប្រចាំខែ តើអ្នកមានជួបប្រទះបញ្ហាអ្វីថ្មីដែរឬទេ?

២. តើសមតុល្យរបស់អ្នកមានលទ្ធផលវិជ្ជមាន ឬ អវិជ្ជមាន? ចូរពន្យល់ពីមូលហេតុ។

៣. តើមានអ្វីប្លែកសម្រាប់ការគ្រោងថវិកាប្រចាំខែថ្មីដែរឬទេ?

៤. តើការគ្រោងថវិកាផ្តល់ផលប្រយោជន៍ដូចម្តេចខ្លះ?

៥. ក្រោយពីបានរៀនធ្វើផែនការកត់ត្រាចំណាយប្រចាំថ្ងៃ និងការធ្វើផែនការថវិកាតើអ្នកឃើញមានការប្រែប្រួលនៅក្នុងទម្លាប់ចំណាយប្រាក់របស់អ្នកដូចម្តេចខ្លះ?

៦. តើអ្នកគិតថា ការគ្រោងថវិកាអាចធ្វើឱ្យមានការប្រែប្រួលជាវិជ្ជមានដល់ទម្លាប់នៃកាចំណាយប្រាក់របស់អ្នកដូចម្តេចខ្លះ?

___

___

___

៧. តើអ្នកគិតថា កំណត់ត្រាចំណាយប្រចាំថ្ងៃអាចធ្វើឱ្យមានការប្រែប្រួលជាវិជ្ជមានដល់ទម្លាប់នៃការចំណាយប្រាក់របស់អ្នកដូចម្តេចខ្លះ?

___

___

___

## មេរៀនទី១៣ : ការធ្វើជំនួញ និង ថវិកាផ្ទាល់ខ្លួន

**☼ លទ្ធផលសិក្សារំពឹងទុក**

ពេលរៀនមេរៀននេះចប់សិស្សនឹងអាច :

- បំពេញតារាងគ្រោងថវិកាចំណាយផ្ទាល់ខ្លួនប្រចាំខែ
- បែងចែកឱ្យច្បាស់រវាង ប្រាក់ចំណាយលើកិច្ចការជំនួញ និងប្រាក់ចំណាយផ្ទាល់ខ្លួន
- បញ្ជាក់ពីមូលហេតុ ស្តីពីសារៈសំខាន់នៃការទុកដាក់ថវិកាទាំងនេះនៅដាច់ដោយឡែកពីគ្នា
- កំណត់វិធីទុកដាក់ថវិកាទាំងនេះ ឱ្យនៅដាច់ដោយឡែកពីគ្នា ។

### ការពិនិត្យឡើងវិញនូវតារាងគ្រោងថវិកាប្រចាំខែផ្ទាល់ខ្លួន

បញ្ហាសំខាន់ដែលទាក់ទងនឹងការប្រកបមុខរបរខ្នាតតូចនៅក្នុងសហគមន៍របស់យើងនោះ គឺកង្វះខាតការយល់ដឹងឱ្យបានច្បាស់រវាងប្រាក់ធ្វើជំនួញ និងប្រាក់ប្រើប្រាស់ផ្ទាល់ខ្លួន ព្រោះពួកគេច្រើនដាក់ប្រាក់ធ្វើជំនួញ និងប្រាក់ប្រើប្រាស់ផ្ទាល់ខ្លួនបញ្ចូលគ្នា ។ អ្នកធ្វើជំនួញភាគច្រើនភ្លេចធ្វើកំណត់សម្គាល់ពីភាពខុសគ្នារវាង ប្រាក់ចំណូល និងប្រាក់ចំណេញ ដែលបណ្តាលឱ្យពួកគេជួបប្រទះកង្វះខាតថវិកាដើម្បីរក្សា ឬធ្វើឱ្យកិច្ចការជំនួញមានការរីកចម្រើន ។ ពួកគេតែងទុកឱ្យកិច្ចការផ្ទាល់ខ្លួនជាប់ទាក់ទងនឹងការអនុវត្តកិច្ចការជំនួញ ។ មេរៀននេះបង្ហាញឱ្យឃើញអំពីសារៈសំខាន់នៃការកំណត់សម្គាល់ភាពខុសគ្នារវាងប្រាក់ធ្វើជំនួញ និង ប្រាក់ផ្ទាល់ខ្លួន ។

១. ចូរលើកឧទាហរណ៍មួយពីប្រភេទមុខជំនួញនៅក្នុងសហគមន៍របស់អ្នក ។

______________________________

២. ប្រភេទមុខជំនួញខាងលើ ( សំណួរ ១) ចូរបញ្ជាក់ការចំណាយមួយចំនួនដែលកើតមាននៅក្នុងមុខជំនួញនេះ ។

______________________________

______________________________

______________________________

៣. ចូរកំណត់ប្រភេទចំណាយជាក់លាក់ ដែលអ្នកធ្វើជំនួញអាចយកទៅអនុវត្តក្នុងគ្រួសាររបស់គាត់ ។

______________________________

៤. ចូរកំណត់តម្រូវការប្រាក់មួយចំនួនដែលកើតមានដោយមិនបានគ្រោងទុកក្នុងការធ្វើជំនួញ ។

៥. ចូរកំណត់តម្រូវការប្រាក់មួយចំនួននៅក្នុងគ្រួសារដែលកើតមានដោយមិនបានគ្រោងទុក ។

| ការបង្ហាញករណីសិក្សាពីតម្រូវការប្រាក់ក្នុងស្ថានភាពចាំបាច់ |
|---|

នេះជាករណីសិក្សាចំនួន ៥ ដែលបង្ហាញពីស្ថានភាពដែលមនុស្សម្នាក់ៗជួបប្រទះនឹងតម្រូវការប្រាក់ជាចាំបាច់ ។

### ករណីសិក្សាទី១ : រឿងរបស់ វ៉ាន់ដា

វ៉ាន់ដា មានហាងតូចមួយនៅផ្ទះល្វែងផ្ទាល់ដី ។ នាងបើកលក់គ្រឿងទេសដូចជា ស៊ុត ហ្គាស ស្ករត្នោត អំបិល ឈើគូស ទៀន អំពូលភ្លើង ។ល។ ប្រសិនបើគាត់ត្រូវការស្ករ អំបិល ឬ របស់របរផ្សេងទៀត សម្រាប់ចំអិនអាហារ គាត់តែងតែយករបស់ដែលមាននៅក្នុងហាងមកប្រើប្រាស់ ។

ពេលខ្លះគាត់បាត់បង់ភ្ញៀវពីព្រោះហាងរបស់គាត់គ្មានទំនិញគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់តម្រូវការភ្ញៀវ ។ គាត់គ្មានប្រាក់គ្រប់គ្រាន់សម្រាប់ទិញទំនិញបន្ថែមមកដាក់លក់នៅក្នុងហាងទេ  ជាញឹកញាប់ គាត់ក៏គ្មានប្រាក់គ្រប់គ្រាន់សម្រាប់ទិញម្ហូបអាហារផ្គត់ផ្គង់គ្រួសារផងដែរ ។ គាត់ឆ្ងល់ណាស់ ហេតុអ្វីបានជាមុខរបររបស់គាត់រកប្រាក់មិនបាន ។ គាត់ត្រូវសុំប្រាក់ពីប្តីរបស់គាត់បន្ថែមទៀតសម្រាប់បន្តមុខរបរនេះ ។

១. តើករណីសិក្សារឿងរបស់ វ៉ាន់ដា មានបញ្ហាអ្វីកើតឡើង?

___

___

___

២. តើ វ៉ាន់ដាអាចមានជម្រើសអ្វីខ្លះចំពោះស្ថានភាពដែលនាងជួបប្រទះ?

___

___

___

៣. តើ វ៉ាន់ដា បានសម្រេចចិត្តយកជម្រើសមួយណា?

___

___

___

៤. តើ វ៉ាន់ដា អាចមានជម្រើសផ្សេងអ្វីខ្លះ?

___

___

___

**ករណីសិក្សាទី២ : រឿងរបស់ សារី**

សារី ជាអ្នកប្រកបមុខរបរធ្វើនំ ។ ជារៀងរាល់ព្រឹកនាងក្រោកពីព្រលឹមដើម្បីធ្វើនំ ។ ពេលធ្វើរួចគាត់តែងទុកនំ ២ សម្រាប់គ្រួសារគាត់ ក្រៅពីនេះគាត់យកទៅលក់ឱ្យហាងនំ ។ ម្ចាស់ហាងបង់ប្រាក់ថ្លៃលក់នំឱ្យគាត់ជារៀងរាល់ថ្ងៃ ហើយថែមទាំងបញ្ជាទិញទុកសម្រាប់លក់នៅថ្ងៃបន្ទាប់ទៀត ។ គាត់មិនដែលទិញអ្វីផ្តេសផ្តាសនោះទេ ។ នៅពេលត្រឡប់មកដល់ផ្ទះវិញ គាត់បានដាក់ប្រាក់ចូលទៅក្នុងហិបពិសេសរបស់គាត់ ដែលលាក់ទុកក្នុងផ្ទះ ។

សារី តែងធ្វើផែនការពីការចំណាយប្រាក់ជានិច្ច ។ ក្នុងមួយសប្តាហ៍គាត់រាប់ប្រាក់ម្តង ដើម្បីចង់ដឹងថាតើគាត់រកបានប្រាក់ប៉ុន្មាន ។ គាត់ពិនិត្យមើលរបស់របរសម្រាប់ផ្គត់ផ្គង់មុខជំនួញរបស់គាត់ ហើយធ្វើការសម្រេចចិត្តថាតើត្រូវការប្រាក់ប៉ុន្មានសម្រាប់ទិញនៅសប្តាហ៍ក្រោយ ។ គាត់តែងពិនិត្យមើលក្រែងមានឧបករណ៍ណាមួយត្រូវផ្លាស់ ។ បន្ទាប់មក សារីពិនិត្យមើលរបស់របរហូបចុកសម្រាប់គ្រួសារដែលត្រូវការបន្ថែម ។ គាត់បានដាក់ប្រាក់មួយផ្នែកចូលទៅក្នុងហោប៉ៅខាងឆ្វេងសម្រាប់ទិញរបស់របរធ្វើនំហើយគាត់ដាក់ប្រាក់មួយផ្នែកទៀត ទៅក្នុងហោប៉ៅខាងស្តាំសម្រាប់ទិញម្ហូបអាហារ ។ គាត់ក៏ដាក់ប្រាក់មួយចំនួនតូចចូលទៅក្នុងហិបវិញសម្រាប់ប្រើប្រាស់ពេលត្រូវការចាំបាច់ ។ បន្ទាប់មកសារីក៏ទៅផ្សារដើម្បីទិញរបស់របរធ្វើនំ និងម្ហូបអាហារ ។ នាងមានប្រាក់គ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់គ្រួសារ ។

១. តើនៅក្នុងករណីសិក្សារបស់ "រឿងរបស់សារិ" មានបញ្ហាអ្វីកើតឡើង?

---

---

---

២. តើ សារីអាចមានជម្រើសអ្វីខ្លះចំពោះស្ថានភាពដែលនាងជួបប្រទះ?

---

---

---

៣. តើ សារី បានសម្រេចចិត្តយកជម្រើសមួយណា?

__________________________________________

__________________________________________

__________________________________________

៤. តើ សារី អាចមានជម្រើសផ្សេងអ្វីខ្លះ?

__________________________________________

__________________________________________

__________________________________________

**ករណីសិក្សាទី៣ :  រឿងរបស់ មីងមួយ**

ក្នុងការខ្ចីប្រាក់កាលពីលើកមុន មីងមួយបានខិតខំធ្វើការយ៉ាងខ្លាំង ដើម្បីរកប្រាក់សងគេ។ គាត់បានទិញបន្លែពីផ្សារនៅទីក្រុងមកលក់នៅតាមផ្ទះក្នុងសហគមន៍។ គាត់រកប្រាក់ចំណេញបានច្រើនណាស់ ពីការខ្ចីប្រាក់លើកមុនមកប្រកបមុខរបរ។

មីងមួយ ឥឡូវខ្ចីប្រាក់ថ្មីបន្តទៀត។ ប្រាក់ដែលគាត់ខ្ចីលើកនេះ មួយផ្នែកគាត់បានយកទៅទិញបន្លែលក់។ ប្រាក់ដែលនៅសល់គាត់យកទៅទិញអង្ករ និង គ្រឿងធ្វើម្ហូបផងដែរ។ គាត់បានសម្រេចចិត្តទិញរទេះរុញដែលល្អជាងមុនមួយសម្រាប់ដាក់លក់ទំនិញរបស់គាត់។

មិត្តរបស់មីងមួយដែលខ្ចីប្រាក់គេដែរនោះ បានមកលេងនឹងគាត់។  មិត្តរបស់មីងមួយម្នាក់នេះមិនបានបង់ប្រាក់ដែលខ្ចីគេជាយូរមកហើយ ព្រោះកូនរបស់គាត់មានជំងឺជាទម្ងន់កាលពីឆ្នាំកន្លងទៅនេះ។ គាត់បានចំណាយប្រាក់ជាច្រើនទៅលើថ្លៃព្យាបាលកូន។ គាត់សុំខ្ចីប្រាក់ខ្លះពីមីងមួយ។

មីងមួយក៏បានពន្យល់ប្រាប់មិត្តគាត់ថា គាត់ត្រូវការប្រើប្រាក់កម្ចីនេះសម្រាប់មុខជំនួញរបស់គាត់។ម្យ៉ាងទៀតគាត់មិនទាន់មានប្រាក់សងគេនៅឡើយទេ។ ប៉ុន្តែមីងមួយបាននិយាយថាខ្ញុំមានប្រាក់មួយចំនួនតូចដែល

# សៀវភៅសិស្ស

បានសន្សំទុកសម្រាប់ពេលត្រូវការជាបន្ទាន់ ។ ប៉ុន្តែអាចខ្ចីប្រាក់នេះបាន ប្រសិនបើមានស្ថានភាពធ្ងន់ធ្ងរបែបនេះ ។ មិត្តរបស់មីងមួយបានអរគុណគាត់ជាខ្លាំង ដែលបានជួយហើយសន្យាថានឹងសងមីងមួយវិញក្នុងពេលមួយសមស្រប ។

ឥឡូវមីងមួយមានទំនិញច្រើនសម្រាប់លក់ ហើយរទេះដែលដាក់ទំនិញរបស់គាត់ក៏ស្អាតទៀត ។ មីងមួយកំពុងតែរកបានប្រាក់ចំណេញច្រើន ហើយគាត់អាចមានលទ្ធភាពសងប្រាក់គេបានយ៉ាងងាយស្រួល ។ គាត់បានសម្រេចចិត្ត ដាក់សន្សំបន្ថែមទៀតជំនួសឱ្យប្រាក់ដែលគាត់បានឱ្យមិត្តភក្តិខ្ចី ។

១. តើនៅក្នុងករណីសិក្សារបស់មីងមួយមានបញ្ហាអ្វីកើតឡើង?

___

___

___

២. តើមីងមួយ អាចមានជម្រើសអ្វីខ្លះចំពោះស្ថានភាពដែលគាត់ជួបប្រទះ?

___

___

___

៣. តើមីងមួយ បានសម្រេចចិត្តយកជម្រើសមួយណា?

___

___

___

៤. តើ មីងមួយ អាចមានជម្រើសផ្សេងអ្វីខ្លះ?

___

___

___

**ករណីសិក្សាទី៤ : រឿងរបស់ រក្សា**

រក្សាជាជាងកាត់ដេរ ។ គាត់កាត់ដេរសំលៀកបំពាក់នៅហាងមួយ ។ ពេលថ្មីៗនេះ គាត់បានបើកមុខជំនួញកាត់ដេរផ្ទាល់ខ្លួន ។ រក្សាបានខ្ចីប្រាក់គេច្រើនជាង២ដងនៃចំនួនប្រាក់ដែលគាត់បានគ្រោង សម្រាប់ធ្វើដើមទុនប្រកបមុខរបររបស់គាត់ ។

រក្សាមានបំណងរៀបចំពិធីជប់លៀង ដើម្បីអបអរសាទរការចាប់ផ្តើមមុខជំនួញរបស់គាត់ ។ រក្សាបានយកប្រាក់ដែលខ្ចីលើសមកធ្វើពិធីជប់លៀង ។

សកម្មភាពធ្វើជំនួញថ្មីរបស់រក្សាបានដំណើរការល្អប្រសើរ ប៉ុន្តែគាត់មិនមានប្រាក់គ្រប់គ្រាន់សងគេឱ្យបានទៀតទាត់នោះទេ ។ រក្សាបានប្រើប្រាក់ដែលខ្ចីលើស ដើម្បីសងបំណុលគេ ។

ដល់កំណត់ថ្ងៃបង់ប្រាក់ រក្សាមិនមានប្រាក់គ្រប់គ្រាន់ ដើម្បីបង់ថ្លៃសងបំណុលសរុបនោះឡើយ ។ គាត់បានប្រមូលប្រាក់ធ្វើជំនួញរបស់គាត់ទាំងអស់យកទៅសងបំណុលគេ ។ គាត់បាត់បង់ម៉ាស៊ីនកាត់ដេររបស់គាត់ និងគ្មានធនធានសម្រាប់បន្តមុខជំនួញរបស់គាត់ទៀតឡើយ ។

១. តើនៅក្នុងករណីសិក្សារបស់ រក្សា មានបញ្ហាអ្វីកើតឡើង?

______________________________

______________________________

______________________________

២. តើ រក្សាអាចមានជម្រើសអ្វីខ្លះចំពោះស្ថានភាពដែលនាងជួបប្រទះ?

______________________________

______________________________

______________________________

៣. តើ រក្សា បានសម្រេចចិត្តយកជម្រើសមួយណា?

---

---

---

៤. តើ រក្សា អាចមានជម្រើសផ្សេងអ្វីខ្លះ?

---

---

---

**ករណីសិក្សាទី៥ : រឿងរបស់ វណ្ណា**

វណ្ណា បានទៅខ្ចីប្រាក់គេ ។ នាងមានផែនការប្រើប្រាក់កម្ចីទាំងអស់ ដើម្បីទិញអង្ករសម្រាប់លក់ ។ នៅពេលគាត់មកដល់ផ្សារ គាត់មិនបានទិញអង្ករទេ តែគាត់បានឃើញសំលៀកបំពាក់ស្អាតៗ ។ គាត់មិនបានទិញសំលៀកបំពាក់ជាយូរមកហើយ ។ គាត់ក៏សម្រេចចិត្តទិញសំលៀកបំពាក់នោះ ។

កូនស្រីរបស់វណ្ណាក៏បានសុំសំលៀកបំពាក់ថ្មីដែរ ។ គាត់ក៏បានទិញឱ្យកូនមួយសម្រាប់ដែរ ។ គាត់នៅសល់ប្រាក់កម្ចីតែពាក់កណ្ដាលប៉ុណ្ណោះ ។ គាត់ក៏ទៅទិញអង្ករសម្រាប់ធ្វើមុខជំនួញរបស់គាត់ ។ គាត់ក៏វិលត្រឡប់ទៅសហគមន៍របស់គាត់វិញដើម្បីលក់អង្ករ ។ គាត់រកប្រាក់ចំណូលបានតិចតួចជាងអ្វីដែលគាត់បានគិត ។ គាត់ស្ទើរតែគ្មានប្រាក់ចាត់ចែងសងបំណុលគេ ។

១. នៅក្នុងករណីសិក្សារបស់ វណ្ណា តើមានបញ្ហាអ្វីកើតឡើង?

---

---

---

២. តើ វណ្ណាអាចមានជម្រើសអ្វីខ្លះចំពោះស្ថានភាពដែលនាងជួបប្រទះ?

______________________________________________

______________________________________________

______________________________________________

៣. តើ វណ្ណា បានសម្រេចចិត្តយកជម្រើសមួយណា?

______________________________________________

______________________________________________

______________________________________________

៤. តើ វណ្ណា អាចមានជម្រើសផ្សេងអ្វីខ្លះ?

______________________________________________

______________________________________________

______________________________________________

### រឿងខ្លីស្តីពីប្រាក់ផ្ទាល់ខ្លួន និង ប្រាក់ធ្វើជំនួញ

នៅក្នុងសៀវភៅកត់ត្រាមេរៀនរបស់អ្នក ចូរសរសេររឿងខ្លីផ្ទាល់ខ្លួនមួយស្តីពីការធ្វើជំនួញ និងប្រាក់ចំណាយផ្ទាល់ខ្លួន។ ការសរសេររឿងនេះត្រូវមានជា ២ វគ្គ : (១) ការសរសេរត្រូវបញ្ចប់ដោយមានខ្លឹមសារបង្ហាញពីមនុស្សណាម្នាក់ ឬក្រុមណាមួយធ្វើការសម្រេចចិត្តប្រើប្រាស់ប្រាក់ដោយឈ្លាសវៃ។ (២) ការសរសេរត្រូវបញ្ចប់ដោយមានខ្លឹមសារបង្ហាញពីមនុស្សណាម្នាក់ ឬក្រុមណាមួយធ្វើការសម្រេចចិត្តប្រើប្រាស់ប្រាក់ដោយមិនឈ្លាសវៃ។

## ខ្លឹមសារសង្ខេបនៃវគ្គសិក្សាការគ្រប់គ្រងប្រាក់

១. ចូរលើកឧទាហរណ៍ពី " **តម្រូវការ** " មួយ ហើយពន្យល់ថាហេតុអ្វីបានជាវាតម្រូវការចាំបាច់។

________________________________________

________________________________________

________________________________________

២. ចូរលើកឧទាហរណ៍ពី " **ចំណង់** " មួយ ហើយពន្យល់ថាហេតុអ្វីបានជាវាជាការចង់បាន។

________________________________________

________________________________________

________________________________________

៣. តើការចំណាយណាមួយដែលងាយស្រួល និង សំខាន់បំផុត? (ចូរគូសរង្វង់ជុំវិញឃ្លានោះ)

ចំណាយថេរ ចំណាយប្រែប្រួល ចំណាយដែលមិនបានគ្រោងទុក ចំណាយលើវត្ថុប្រណិត

៤. តើ "**ទម្លាប់ចំណាយប្រាក់**" បែបណាដែលអ្នកចាត់ទុកថាល្អ ឬ សមរម្យ?

________________________________________

________________________________________

________________________________________

៥. តើអ្នកគិតថានឹងកែលំអ " **ទម្លាប់ចំណាយប្រាក់** " តាមវិធីណាខ្លះ?

________________________________________

________________________________________

________________________________________

៦. តើអ្វីដែលជាគោលបំណងសំខាន់សម្រាប់អ្នក?

៧. តើអ្នកមានសកម្មភាពអ្វីខ្លះ ដែលអ្នកត្រូវធ្វើ ដើម្បីឱ្យសម្រេចគោលបំណងនេះ?

៨. តើអ្នកត្រូវផ្លាស់ប្តូរ " **ទម្លាប់ចំណាយប្រាក់** " ដើម្បីធ្វើឱ្យមានប្រាក់សម្រេចគោលបំណងធ្វើជំនួញរបស់អ្នកឬទេ? ចូរពន្យល់

៩. តើអ្វីដែលជាសារៈសំខាន់នៃការប្រើប្រាស់សៀវភៅកំណត់ត្រាចំណាយ?

១០. តើសារប្រយោជន៍នៃការបង្កើតថវិកាមានអ្វីខ្លះ?

# សៀវភៅសិស្ស

១១. ហេតុអ្វីបានជាថវិកាអាចមានការប្រែប្រួលគ្រប់ពេល?

១២. ចូរពន្យល់ពីសារៈសំខាន់នៃការរៀបចំបញ្ជីគណនេយ្យ ។

១៣. តើអ្វីដែលជាចំណុចសំខាន់ត្រូវពិចារណា ពេលអ្នកធ្វើការកំណត់តម្លៃទំនិញសម្រាប់លក់?

១៤. ចូរលើកហេតុផល ៣ យ៉ាង ដើម្បីបញ្ជាក់ពីសារៈសំខាន់ក្នុងការរក្សាទុកប្រាក់ធ្វើជំនួញ និង ប្រាក់ផ្ទាល់ខ្លួននៅដាច់ពីគ្នា ។

## ឧបសម្ព័ន្ធ ១.១ : ទម្រង់បណ្ណវាយតម្លៃ (សម្រាប់គ្រូ)

### បណ្ណវាយតម្លៃការសិក្សារបស់សិស្សម្នាក់ៗ

ឈ្មោះសិស្ស ________ សាលា ________ ឃុំ ______ ស្រុក ______ ថ្នាក់ទី ___ ឆ្នាំសិក្សា ______

| | ចំណុចត្រូវដាក់ពិន្ទុ | ពិន្ទុ (១-១៥) | និទ្ទេស |
|---|---|---|---|
| | **វិញ្ញាសាទី ១: [illegible]** | | |
| | [illegible] ពិន្ទុសរុប ១៥ ពិន្ទុ បើពិន្ទុ ០ ដល់ ៧-ខ្សោយ/ បើ ៨ ដល់ ១០-មធ្យម / បើ ១១ ដល់ ១៥-ល្អ) | | |
| | **សង្កេតឥរិយាបថសិស្ស** | **ពិន្ទុ (១-៥)** | **និទ្ទេស** |
| ១ | **[illegible] :** [illegible] ។ | | |
| ២ | **[illegible] :** [illegible] ។ | | |
| ៣ | **[illegible] :** [illegible] ។ | | |
| ៤ | **[illegible] :** [illegible] ។ | | |
| ៥ | **[illegible] :** [illegible] ។ | | |
| ៦ | **[illegible] :** [illegible] ។ | | |
| ៧ | **[illegible] :** [illegible] ។ | | |
| | សរុបសង្កេតឥរិយាបថសិស្ស | | |
| | [illegible] ពិន្ទុសរុប ៣៥ ពិន្ទុ (បើពិន្ទុ ០ ដល់ ១៧-ខ្សោយ/ បើ ១៨ ដល់ ២៣-មធ្យម / បើ ២៤ ដល់ ៣៥-ល្អ) | | |
| | ពិន្ទុសរុបសំណួរសរសេរ និងសង្កេតឥរិយាបថសិស្ស (បើពិន្ទុ ០ ដល់ ២៤-ខ្សោយ/ បើ ២៥ ដល់ ៣៣-មធ្យម / បើ ៣៤ ដល់ ៥០-ល្អ) | | |

ថ្ងៃទី ______ ខែ ______ ឆ្នាំ ______

ហត្ថលេខា និងឈ្មោះគ្រូ

## ឧបសម្ព័ន្ធ ១.២ : តារាងបូកសរុបរង្វាយតម្លៃការសិក្សារបស់សិស្សប្រចាំថ្នាក់

ខេត្ត ......................... ស្រុក .......................សាលា ............................ ថ្នាក់ទី .......... ប្រធានបទ ...................

| ល.រ | ឈ្មោះសិស្ស | សំណួរសរសេរ | | ឥរិយាបថ | | សរុប | |
|---|---|---|---|---|---|---|---|
| | | ពិន្ទុ | និទ្ទេស | ពិន្ទុ | និទ្ទេស | ពិន្ទុ | និទ្ទេស |
| ១ | | | | | | | |
| ២ | | | | | | | |
| ៣ | | | | | | | |
| ៤ | | | | | | | |
| ៥ | | | | | | | |
| ៦ | | | | | | | |
| ៧ | | | | | | | |
| ៨ | | | | | | | |
| ៩ | | | | | | | |
| ១០ | | | | | | | |
| ១១ | | | | | | | |
| ១២ | | | | | | | |
| ១៣ | | | | | | | |
| ១៤ | | | | | | | |
| ១៥ | | | | | | | |
| ១៦ | | | | | | | |
| ១៧ | | | | | | | |
| ១៨ | | | | | | | |
| ១៩ | | | | | | | |
| ២០ | | | | | | | |
| ២១ | | | | | | | |
| ២២ | | | | | | | |
| ២៣ | | | | | | | |
| ២៤ | | | | | | | |
| ២៥ | | | | | | | |
| ២៦ | | | | | | | |

បានឃើញ និងឯកភាព　　　　　　　　ថ្ងៃទី .......... ខែ ............ ឆ្នាំ ..........

នាយកសាលា　　　　　　　　ហត្ថលេខា និងឈ្មោះគ្រូបង្រៀន

| ការអង្កេតថ្នាក់រៀន | | | | ការវាយតម្លៃគ្រូបំណិនជីវិត | |
|---|---|---|---|---|---|
| សាលា | | | | គ្រូ | អ្នកសង្កេត |
| | | | | | |
| កាលបរិច្ឆេទ | ការចាប់ផ្តើមមេរៀន | ការបញ្ចប់មេរៀន | ថ្នាក់ | ចំនួនសិស្សដែលបានចុះឈ្មោះ/មានវត្តមាន | ប្រធានបទបំណិនជីវិត: |
| | | | | | |
| តើមេរៀនបង្ហាញពីអ្វី? | | | | | |
| | | | | | |

| លក្ខណៈវិនិច្ឆ័យ – ការរៀបចំ – តើបន្ទប់រៀន.. | ពិន្ទុ | កំណត់សម្គាល់យោងតាមភស្តុតាង |
|---|---|---|
| មានសណ្តាប់ធ្នាប់ ហើយសម្ភារត្រៀមជាស្រេចសម្រាប់ប្រើប្រាស់ក្នុងមេរៀននេះ? | 1-2-3-4-5 | |
| បង្ហាញសិស្សនូវសម្ភារៈដែលបានធ្វើកាលពីមេរៀនមុន? | 1-2-3-4-5 | |
| **លក្ខណៈវិនិច្ឆ័យ - ការសិក្សា - តើសិស្ស...** | **ពិន្ទុ** | **កំណត់សម្គាល់យោងតាមភស្តុតាង** |
| **មានចំណាប់អារម្មណ៍ និងចូលរួមក្នុងការងាររបស់ពួកគេ** | **1-2-3-4-5** | |
| **ធ្វើការក្នុងក្រុមខុសៗគ្នាក្នុងកំឡុងពេលបង្រៀន ដោយមានតួនាទីក្រុមច្បាស់លាស់** | **1-2-3-4-5** | |
| **រីករាយជាមួយមេរៀនដែលគ្រូបង្រៀន** | **1-2-3-4-5** | |
| **បង្ហាញចំណេះដឹង ឬបំណិនពីមេរៀនមុន** | **1-2-3-4-5** | |
| **លក្ខណៈវិនិច្ឆ័យ – ការបង្រៀន – តើគ្រូ..** | **ពិន្ទុ** | **កំណត់សម្គាល់យោងតាមភស្តុតាង** |
| **អនុវត្តតាមកិច្ចតែងការដែលមាន?** | **1-2-3-4-5** | ***សូមបញ្ជាក់ជាគុណភាពមួយដែលត្រូវបានប្រើ*** |
| **ប្រើប្រាស់ធនធានសហគមន៍ក្នុងការបង្រៀនមេរៀននេះ ឬប្រើប្រាស់សហគមន៍ទាំងស្រុង?** | **1-2-3-4-5** | |

| | | |
|---|---|---|
| ប្រើប្រាស់វិធីសាស្ត្របង្រៀនបែបអន្តរកម្ម ឧ.ដៃគូ គំនិត, ករណីសិក្សា, ការសម្តែងតួ,ល្បែងកំសាន្ត... | 1-2-3-4-5 | |
| ប្រើប្រាស់ប្រភេទសំណួរផ្សេងៗ | 1-2-3-4-5 | |
| ប្រើប្រាស់ធនធានបង្កើតឡើងដោយខ្លួនឯង ឬរក សាបន្ថែមដើម្បីពន្យល់មេរៀន | 1-2-3-4-5 | |
| ចាប់ផ្តើមតាមពេលកំណត់ និងប្រើប្រាស់ពេល វេលាយ៉ាងមានប្រសិទ្ធភាព | 1-2-3-4-5 | |
| ផ្តល់មតិយោបល់វិជ្ជមានដើម្បីជំរុញការសិក្សា និងបង្កើនទំនុកចិត្តរបស់សិស្ស | 1-2-3-4-5 | |
| ជួយសិស្សតាមលក្ខណៈបុគ្គលចំពោះសិស្សណាដែលមានការលំបាក | 1-2-3-4-5 | |
| កត់ត្រាការវិវត្តនៃអត្តចរិតសិស្សក្នុងតារាងវាយតម្លៃការសិក្សារបស់សិស្ស? | 1-2-3-4-5 | |

បន្ទាប់ពីផ្នែកនេះ ចូរប្រើប្រាស់កំណត់ត្រារបស់អ្នកដើម្បីពិភាក្សាជាមួយគ្រូ សុំឱ្យគ្រូកំណត់ចំណុចល្អរបស់មេរៀន ហើយធ្វើការស្នើសុំការផ្លាស់ប្តូរ ឬការកែលម្អ ធ្វើការជាមួយគ្រូដើម្បីកំណត់ភាពខ្លាំងៗ ធ្វើការផ្តល់គំនិតចំពោះការកែលម្អ ការសង្កេតត្រូវបានបញ្ចប់ ដោយធ្វើការសម្អាសន៍។

| ចំណុចខ្លាំង | គំនិតសម្រាប់កែលម្អ |
|---|---|
| | |

ហត្ថលេខានិងឈ្មោះរបស់អ្នកវាយតម្លៃ ....................

ហត្ថលេខានិងឈ្មោះរបស់គ្រូ ................................


X
ចំណង់ ឬ តម្រូវការ
✓
មិត្តភ័ក្ត
ការងារ
វត្តអារាម ឬ វិហារអ៊ីស្លាម
សាលារៀន
លុយជាច្រើន
ទូរទស្សន៍
កុំព្យូទ័រផ្ទាល់ខ្លួន
ម៉ូតូថ្មី
ស្ករគ្រាប់ និង នំស្រួយ
សម្រាកពេញមួយថ្ងៃ
គ្រឿងអលង្ការ
ការថែរក្សាជម្ងឺពីគ្រូពេទ្យ
ឡានឡិចស៊ីស
ការការពារពី ការរំលោភបំពាន ឬ ការប្រមាថ
បន្ទប់គេងផ្ទាល់ខ្លួន
ឈប់
STOP
អាហារភ្លាមៗ
សិទ្ធសម្រាប់ការពារពីការរើសអើង
អាហារូបត្ថម្ភ
សំលៀកបំពាក់ និង ម៉ូដនិយមថ្មី
ទឹកស្អាត
កន្លែងកំសាន្ត និងការកំសាន្តសប្បាយ
ទូរស័ព្ទថ្មី
សេរីភាពដើម្បីប្រតិបត្តិវប្បធម៌របស់ខ្លួនផ្ទាល់
ការបញ្ចេញមតិយោបល់
USAID
local life skills pilot-business and economy-my money management
needs and wants lesson 1

# រូបិយវត្ថុកម្ពុជា



ប្រភេទក្រដាសប្រាក់: ៥០រៀល
ទំហំ: ១៣០មម x ៦០មម
ឆ្នាំបោះពុម្ព: ២០០២
ពណ៌ផ្ទៃ: លឿងទុំ
ពណ៌នា: ផ្នែកកណ្តាលនៃក្រដាសប្រាក់រំលេចឡើងនូវរូបក្លោងទ្វារប្រាសាទបន្ទាយស្រី។ ផ្នែកខាងស្តាំមានរូបនរៈសិង្ហ និងផ្នែកខាងឆ្វេងមានរូបចម្លាក់ក្បាលនាគ។



ប្រភេទក្រដាសប្រាក់: ១០០រៀល
ទំហំ: ១៣០មម x ៦០មម
ឆ្នាំបោះពុម្ព: ២០០១
ពណ៌ផ្ទៃ: ស្វាយ និងបៃតង
ពណ៌នា: រំលេចឡើងនូវទិដ្ឋភាពនៃសាលារៀនមួយខ្នង និងសិស្សានុសិស្សកំពុងដើរសំដៅទៅកាន់ថ្នាក់រៀនរបស់ខ្លួន។



ប្រភេទក្រដាសប្រាក់: ៥០០រៀល
ទំហំ: ១៣៨មម x ៦៨មម
ឆ្នាំបោះពុម្ព: ២០០៣
ពណ៌ផ្ទៃ: ក្រហម
ពណ៌នា: រូបភាពស្ពានគីស្សិណា "កម្ពុជា-ជប៉ុនដែលឆ្លងកាត់ទន្លេមេគង្គ ស្ថិតក្នុងទីរួមខេត្តកំពង់ចាម។



ប្រភេទក្រដាសប្រាក់: ១០០០រៀល
ទំហំ: ១៣៨មម x ៦៨មម
ឆ្នាំបោះពុម្ព: ២០០៦
ពណ៌ផ្ទៃ: ឈាមជ្រូក និងខៀវ
ពណ៌នា: រូបភាពកំពង់ផែខេត្តព្រះសីហនុ ដែលកំពុងមានសកម្មភាពមមាញឹកក្នុងការលើកដាក់ទំនិញ។



ប្រភេទក្រដាសប្រាក់: ២០០០រៀល
ទំហំ: ១៤៦មម x ៦៨មម
ឆ្នាំបោះពុម្ព: ២០០៨
ពណ៌ផ្ទៃ: បៃតងក្រមៅ និងលឿង
ពណ៌នា: រូបទ្វារប្រាសាទព្រះវិហារ និងអក្សរ "ពីរពាន់រៀល" នៅពីខាងក្រោម។



ប្រភេទក្រដាសប្រាក់: ៥០០០រៀល
ទំហំ: ១៤៦មម x ៦៨មម
ឆ្នាំបោះពុម្ព: ២០០១
ពណ៌ផ្ទៃ: ប្រផេះ និងបៃតង
ពណ៌នា: រូបស្ពានបុរាណនៅកំពង់ក្តី ខេត្តសៀមរាប។



ប្រភេទក្រដាសប្រាក់: ១០០០០រៀល
ទំហំ: ១៤៦មម x ៦៨មម
ឆ្នាំបោះពុម្ព: ២០០១
ពណ៌ផ្ទៃ: ពណ៌ស្វាយ ពណ៌ត្នោត និងខៀវ
ពណ៌នា: រូបភាពពិធីបុណ្យអុំទូកនៅមុខព្រះបរមរាជវាំង។



ប្រភេទក្រដាសប្រាក់: ២០០០០រៀល
ទំហំ: ១៥០មម x ៧០មម
ឆ្នាំបោះពុម្ព: ២០០៨
ពណ៌ផ្ទៃ: ស៊ីជម្ពូ និងពណ៌ខៀវ
ពណ៌នា: រូបភាពប្រាសាទអង្គរធំទាំងមូលមើលបញ្ឆិតពីលើ និងរូបចម្លាក់ព្រហ្មមុខបួននៃប្រាសាទបាយ័ន។



ប្រភេទក្រដាសប្រាក់: ៥០០០០រៀល
ទំហំ: ១៥០មម x ៧០មម
ឆ្នាំបោះពុម្ព: ២០០១
ពណ៌ផ្ទៃ: លឿង ឈាមជ្រូក និងត្នោត
ពណ៌នា: រូបភាពប្រាសាទអង្គរវត្ត មើលបញ្ឆិតពីលើ។

ក្រសួងកិច្ចការនារី

MINISTERIO
DE ASUNTOS EXTERIORES
Y DE COOPERACIÓN

aecid

កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH